សមាសភាគកសាងផែនការបន្ស៊ាំ និងភាពធន់នៅតំបន់ឆ្នេរ

# យន្តការដែលមានប្រសិទ្ធភាពសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅក្នុងការកសាងផែនការថ្នាក់ក្រោមជាតិ



Cambodia Climate Change Alliance (CCCA)

Implemented by: Supported by:

Ministry of Environment

European Union

UNDP

Empowered lives Resilient nations

Danida

SWEDEN

UNEP-DHI CENTRE
for Water and Environment

UNEP DHI

២០១៤

# មាតិកាអត្ថបទ


**បុព្វកថា** ........ iii

**សេចក្តីថ្លែងអំណរគុណ** ........ v

**សេចក្តីសង្ខេប** ........ vi

I. **សាវតា** ........ ១

១.១ គោលបំណង និងវិធាន ........ ១

១.២ ផែនការវិនិយោគឃុំ សម្រាប់ឃុំគោលដៅ ........ ១

II. **ទិដ្ឋភាពរួមនៃការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ** ........ ២

២.១ រចនាសម្ព័ន្ធស្ថាប័ន ........ ២

២.២ ដំណើរការកសាងផែនការ ........ ៣

III. **ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ** ........ ៦

៣.១ រចនាសម្ព័ន្ធស្ថាប័ន ........ ៦

៣.២ នីតិវិធី និងដំណើរការសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ ........ ៨

៣.៣ វិធាននៃដំណើរការដែលប្រើប្រាស់សម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ........ ១២

IV. **សំណើយន្តការសម្របសម្រួលសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ** ........ ១៥

V. **ទំនាក់ទំនងរវាងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** ........ ១៧

VI. **សេចក្តីសន្និដ្ឋាន** ........ ១៨

**ឯកសារយោង** ........ ២០

**ឧបសម្ព័ន្ធ – ផែនការវិនិយោគឃុំ និងសំណើគម្រោងខ្នាតតូច** ........ ២០

## បុព្វកថា

ខ្ញុំមានក្ដីសោមនស្សរីករាយ សូមបង្ហាញរបាយការណ៍ ស្ដីពីយន្តការមានប្រសិទ្ធភាពសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅក្នុងការកសាងផែនការថ្នាក់ក្រោមជាតិ ដែលជាសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាវវាងស្ថាប័នរដ្ឋគ្រប់កំរិត ដូចជា ថ្នាក់ខេត្ត ស្រុក និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ គម្រោង និងកម្មវិធីដែលទាក់ទងជាមួយការអភិវឌ្ឍន៍តំបន់ឆ្នេរ និងការប្រែប្រួលអាកាសធាតុ។ របាយការណ៍នេះ នឹងរៀបរាប់សង្ខេបពីសកម្មភាពអនុវត្តគម្រោង និងវិធីសាស្ត្រដើម្បីបញ្ជ្រាបសកម្មភាព និងវិធីសាស្ត្រការបន្សាំការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងរៀបចំរចនាសម្ព័ន្ធ និងកសាងសមត្ថភាព ដើម្បីអនុវត្តន៍វិធានការបន្សាំការប្រែប្រួលអាកាសធាតុ។

របាយការណ៍នេះ រៀបរាប់អំពីយន្តការដែលមានប្រសិទ្ធភាពសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅក្នុងការកសាងផែនការ ថ្នាក់ក្រោមជាតិ ដោយផ្អែកលើបទពិសោធន៍ដែលទទួលបានតាមរយៈការអនុវត្តគម្រោងក្នុងឃុំចំនួន ០៦ ក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងឃុំចំនួន០២ នៅស្រុកមណ្ឌលសីមា ខេត្តកោះកុង។ របាយការណ៍នេះ នឹងរៀបរាប់ដោយសង្ខេប ស្ដីពីសកម្មភាពបញ្ជ្រាបដោយដាក់បញ្ចូលនូវវិធានការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ/ផែនការវិនិយោគឃុំ តាមរយៈសិក្ខាសាលាធ្វើសមាហរណកម្មថ្នាក់ស្រុក និងអនុសាសន៍ ស្ដីពីការបង្កើតអង្គភាពសម្របសម្រួលការប្រែប្រួលអាកាសធាតុនៅថ្នាក់ខេត្ត និងផ្ដល់ទស្សនៈក្នុងការបង្កើតរចនាសម្ព័ន្ធសម្រាប់បន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងវិធីសាស្ត្រសម្រាប់សហគមន៍ធ្វើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងនៅពេលជាមួយគ្នានេះ វាអាចធ្វើការកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។ របាយការណ៍នេះ នឹងបង្ហាញពីផែនការវិនិយោគដែលបានរៀបចំឡើងសម្រាប់ឃុំគោលដៅអនុវត្តគម្រោងនីមួយៗ។

ភាពសម្បូរណ៍បែបនៃធនធានធម្មជាតិ និងបរិស្ថាននៅតំបន់ឆ្នេរសមុទ្រកម្ពុជា បានរងផលប៉ះពាល់រយៈពេលជាច្រើនឆ្នាំពីសកម្មភាពអភិវឌ្ឍន៍។ លើសពីនេះទៀត ការប្រែប្រួលអាកាសធាតុក៏បង្កឲ្យមានផលប៉ះពាល់ដល់ជីវភាពរស់នៅតំបន់ឆ្នេរសមុទ្រ ជាពិសេសតំបន់ទំនាបដូចជា ទឹកជំនន់ ការជ្រាបចូលទឹកសមុទ្រ និងការហូរច្រោះឆ្នេរ ។ សេចក្ដីត្រូវការ លើការកែលម្អលើការគ្រប់គ្រង គឺដើម្បីធានាដល់ការកែលម្អដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៅក្នុងតំបន់ដោយមិនបង្កឲ្យមានផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាន ជាពិសេស វាជាការបន្ទាន់ទាក់ទងនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុចំពោះជីវភាពរស់នៅនាពេលបច្ចុប្បន្ន ដែលសហគមន៍តំបន់ឆ្នេរកំពុងតែបង្កើតការបន្សាំ និងបង្កើនភាពធន់ដល់សហគមន៍។ នៅពេលជាមួយគ្នា វាអាចប្រើប្រាស់សម្រាប់អនុវត្ត និងពង្រីកទៅផ្នែកដ៏ទៃទៀតនៅតំបន់ឆ្នេរ និងខេត្តដ៏ទៃទៀត។

របាយការណ៍នេះ មានសារៈសំខាន់ចំពោះអាជ្ញាធរឃុំ ស្រុក និងខេត្ត ព្រមទាំងមន្ទីរជំនាញនៅក្នុងខេត្តនៅតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព។ របាយការណ៍នេះ នឹងបង្ហាញពីសារប្រយោជន៍ដល់អ្នកអានមានដូចជា អ្នករៀបចំគោលនយោបាយនៅថ្នាក់ជាតិ អ្នកធ្វើផែនការ និងស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល គម្រោងផ្សេងៗ និងផ្នែកឯកជន ព្រមទាំងជាមូលដ្ឋានដល់ការអប់រំ ការស្រាវជ្រាវផងដែរ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អ្នកអានទាំងអស់នឹងស្វែងយល់ពីរបាយការណ៍នេះ ដែលជាធនធានដ៏មានតម្លៃសម្រាប់ការងារការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១៤

**អគ្គនាយកបច្ចេកទេស**
**និងជាប្រធានគណៈកម្មាធិការដឹកនាំគម្រោង**

**បណ្ឌ. ឡុញ ហ៊ាល**

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ ត្រូវបានរៀបរៀងឡើងនៅក្រោមសមាសភាគកសាងផែនការបន្សុាំ និងភាពធន់ក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា ក្រោមកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ របកគំហើញ ក្នុងរបាយការណ៍នេះ បានផ្អែកលើមេរៀន និងបទពិសោធន៍នានា ដែលទទួលបានពីសកម្មភាពដែលអនុវត្តនៅក្រោមសមាសភាគនេះ។

តាងនាមឲ្យក្រុមការងារតំបន់ឆ្នេរសមុទ្រកម្ពុជា ខ្ញុំបាទសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាអនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលតែងតែជម្រុញ ណែនាំ និងគាំទ្រយ៉ាងខ្លាំងក្លាដល់កិច្ចប្រឹងប្រែងរបស់ក្រុមការងារ ដើម្បីសម្រេចបានរបាយការណ៍នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោក លោកស្រី ជាសមាជិកគណៈកម្មាធិការដឹកនាំគម្រោង ក្រុមការងារជនបង្គោលថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត ទីប្រឹក្សាជាតិ និងអន្តរជាតិ រួមទាំងភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកផ្តល់មតិល្អៗ ចំពោះការចងក្រងរបាយការណ៍នេះ ។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ចំពោះការឧបត្ថម្ភគាំទ្រដល់សមាសភាគកសាងផែនការ និងភាពធន់ដល់ប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមរយៈភ្នាក់ងារអនុវត្ត DHI សហការល្អជាមួយក្រសួងបរិស្ថាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤

**គណៈកម្មាធិការដឹកនាំគម្រោង**

**អនុប្រធានអចិន្ត្រៃយ៍**

**បណ្ឌិត វ៉ាន់ មុនីនាថ**

# សេចក្តីសង្ខេប

ការកសាងផែនការ និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ កំពុងធ្វើឡើងនៅលំដាប់ថ្នាក់ខុសៗគ្នា ដោយមានវឌ្ឍនភាពគួរឲ្យកត់សំគាល់នៅថ្នាក់ជាតិ។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យ ត្រូវបានអនុម័ត ដែលផ្តល់ជាក្របខ័ណ្ឌគោលនយោបាយទូលំទូលាយមួយសម្រាប់រួមបញ្ចូលការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ កិច្ចផ្តួចផ្តើម និងគម្រោងកំពុងអនុវត្តមួយចំនួន ត្រូវបានអនុវត្តនៅថ្នាក់ជាតិ ដោយប្រើប្រាស់វិធីនៃការកសាងផែនការរបស់រដ្ឋាភិបាល និងទម្លាប់ជាអន្តរជាតិ។ សមាសភាគកសាងផែនការបន្សាំ និងភាពធន់នឹងអាកាសធាតុក្នុងតំបន់ឆ្នេរនៃ CCCA ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ ២០១២មក នៅក្នុងឃុំចំនួន ៨ ក្នុងស្រុកព្រៃនប់ និងមណ្ឌលសីមា ក្នុងខេត្តព្រះសីហនុ និងខេត្តកោះកុង។ វិធាន CARP ពោលគឺ ការអនុវត្តសកម្មភាពបង្ហាញ និងការរួមបញ្ចូលការគិតគូរអំពីការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ បានផ្អែកលើនីតិវិធីកសាងផែនការដែលមានបច្ចុប្បន្នរបស់រដ្ឋាភិបាល និងគោលការណ៍ណែនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បទពិសោធន៍របស់ CARP បង្ហាញអំពីវត្តមានឱកាសសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (DP5) និងកម្មវិធីវិនិយោគរំកិលរយៈពេលបីឆ្នាំ (IP3)។ ទោះជាយ៉ាងណាក៏ដោយ កង្វះរចនាសម្ព័ន្ធស្ថាប័នជាផ្លូវការ និងគោលការណ៍ណែនាំនឹងធ្វើឲ្យមានការលំបាកក្នុងការរក្សាដំណើរការនៃការងារនេះនៅថ្នាក់ក្រោមជាតិ។ ផ្អែកតាមការវិភាគទូលំទូលាយអំពីរចនាសម្ព័ន្ធស្ថាប័នដែលមានស្រាប់សម្រាប់ការកសាងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងដោយគិតគូរផងដែរអំពីប៉ារ៉ាម៉ែត្រនានានៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលកំពុងអនុវត្ត ការបង្កើតអង្គភាពសម្របសម្រួលការប្រែប្រួលអាកាសធាតុ ដែលជាផ្នែកមួយនៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) ត្រូវបានស្នើឡើង។ ការធ្វើបែបនេះនឹងអាចទាញយកផលពីសមត្ថភាពដែលបានអភិវឌ្ឍន៍រួចមកហើយ នៅក្នុងក្រុមការងារបច្ចេកទេសនានា និងអាចជ្រើសរើសសមាជិកបន្ថែមទៀត ដោយប្រើប្រាស់វិធាន និងបទប្បញ្ញត្តិនៃគោលការណ៍វិមជ្ឈការ និងវិសហជ្ឈការ (D&D)។ កិច្ចការចំបងគឺកែលម្អការកសាងផែនការ និងនីតិវិធីលើកថវិកាលើកកំពស់ការអភិវឌ្ឍសមត្ថភាព និងបង្កើតប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ (M&E) សម្រាប់ការកសាងផែនការ និងការអនុវត្តការងារប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ។ នៅពេលដាក់ឲ្យប្រើប្រាស់ក្របខ័ណ្ឌស្ថាប័នដែលបានកែលម្អសម្រាប់ការកសាងផែនការ និងការអនុវត្តការងារប្រែប្រួលអាកាសធាតុ សកម្មភាពដែលកំពុងអនុវត្តត្រូវបានរំពឹងថានឹងត្រូវពង្រីកទៅក្នុងបណ្តាខេត្តតំបន់ឆ្នេរ និងដែនទឹកសាបបន្ថែមទៀតផងដែរ។

សមាសភាគ CARP មានការប្តេជ្ញាមោះមុតក្នុងការពិភាក្សាជាបន្ត ចែករម្លែកលទ្ធផលនៃការសង្កេតយោបល់ និងអនុសាសន៍នានាដែលគាំទ្រដល់ការវិវត្តនៃដំណើរការបញ្ជ្រាបនៅថ្នាក់ជាតិ។ NCDD និងក្រសួងផែនការ (MOP) ត្រូវបានគេមើលឃើញថាជាដៃគូសំខាន់នៅក្នុងការងារនេះ ដោយមាន NCCC និងលេខាធិការដ្ឋានផ្តល់ការគាំទ្រដ៏សំខាន់តាមរូបភាពជាច្រើន ដែលរួមទាំងជម្រុញឲ្យមានភាពបំពេញគ្នារវាងវិស័យនានាផងដែរ។

ឧបសម្ព័ន្ធនៃរបាយការណ៍នេះអធិប្បាយសកម្មភាពបង្ហាញដែលបានអនុវត្តនៅក្នុងឃុំទាំងប្រាំបីតាមទម្រង់ដែលប្រើប្រាស់នៅក្នុងផែនការវិនិយោគឃុំ (CIPs)។

# I. សាវតា

## ១.១ គោលបំណង និងវិធាន

គម្រោងកសាងផែនការបន្សាំ និងភាពធន់ក្នុងតំបន់ឆ្នេរ (CARP) ត្រូវបានបង្កើតឡើង ដើម្បីបង្កើនភាពធន់នៃសហគមន៍ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ឆ្នេរតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការកសាងផែនការបន្សាំ ការអនុវត្តបង្ហាញដែលផ្តោតលើអន្តរាគមន៍នៅមូលដ្ឋាន និងការផ្តល់លំហាត់ជាក់ស្តែងសម្រាប់ការរៀនសូត្រនៅក្រោមក្របខ័ណ្ឌស្ថាប័ននៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ(NCCC) និងនាយកដ្ឋានប្រែប្រួលអាកាសធាតុ។ CARP គឺជាសមាភាគមួយនៃសំណុំគម្រោងនៅក្រោមសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ។ គោលបំណងចំបងនៃ CARP រួមមាន: i) លើកកំពស់ចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុត្រូវបានដាក់បញ្ចូលទៅក្នុងការប្រើប្រាស់ដី និងផែនការអភិវឌ្ឍន៍តំបន់ឆ្នេរ; ii) កំណើនភាពធន់នៃសហគមន៍តំបន់ឆ្នេរ និងប្រព័ន្ធតំបន់ទំនាប់ក្នុងតំបន់ឆ្នេរ សម្រាប់ទប់ទល់នឹងការប្រែប្រួលអាកាសធាតុ និងកំណែលម្អរបរចិញ្ចឹមជីវិតក្នុងតំបន់ឆ្នេរ។ ការបង្កើតយន្តការសម្របសម្រួលសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ គឺជាផ្នែកមួយនៃកិច្ចការ"សមាហរណកម្មការគិតគូរអំពីការប្រែប្រួលអាកាសធាតុសម្រាប់តំបន់ឆ្នេរទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ (CDP) និងកម្មវិធីវិនិយោគឃុំ និងយន្តការប្រែប្រួលអាកាសធាតុដែលបានបង្កើត"។ យន្តការសម្របសម្រួលនេះត្រូវបានរៀបចំឡើងដោយផ្អែកលើ ១)ការវិភាគរចនាសម្ព័ន្ធស្ថាប័នដែលមានបច្ចុប្បន្នសម្រាប់ការកសាងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និង ២) បទពិសោធន៍ជាមួយវឌ្ឍនភាពដែលធ្វើឡើងតាមរយៈកិច្ចផ្តួចផ្តើមនិងគម្រោងមួយចំនួនដែលបានអនុវត្តនៅលំដាប់ថ្នាក់ខុសៗគ្នា ដែលរួមទាំងការអនុវត្តគម្រោងបង្ហាញខុសៗ គ្នាអំពីការបន្សាំចំនួនប្រាំមួយនិងការរួមបញ្ចូលគម្រោងទាំងនោះទៅក្នុងCDPs និងកម្មវិធីវិនិយោគឃុំ(CIP)។ ការវិភាគរបកគំហើញ និងមេរៀនទទួលបាន បានជួយបង្កើនការយល់ដឹងរបស់យើងអំពីឱកាស និងការប្រឈមនានាដែលទាក់ទងនឹងការកសាងផែនការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ១.២ ផែនការវិនិយោគឃុំ សម្រាប់ឃុំគោលដៅ

នៅក្នុងឧបសម្ព័ន្ធ ១-៨ សកម្មភាពបង្ហាញត្រូវបានអធិប្បាយ អនុលោមតាមគំរូដែលប្រើប្រាស់សម្រាប់ CIPs, ដែលផ្តល់ចំណុចពិស្តារចាំបាច់។ លើសពីនេះ គំរូជាក់លាក់មួយត្រូវបានដាក់បញ្ចូល ដែលផ្តោតលើការគិតគូរអំពីការប្រែប្រួលអាកាសធាតុ ធៀបនឹងគម្រោងបង្ហាញ។

ផែនការ CIPs ដែលរួមទាំង សកម្មភាពបង្ហាញអំពីការប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើងសម្រាប់ឃុំនានាដូចតទៅ៖

០៥០២: ឃុំពាមក្រសោប ស្រុកមណ្ឌលសីមា

០៥០៣: ឃុំទួលគរគី ស្រុកមណ្ឌលសីមា

០២០៦: ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់

០២០៧: ឃុំព្រៃនប់ ស្រុកព្រៃនប់

០២០៩: ឃុំសាមគ្គី ស្រុកព្រៃនប់

០២១១: ឃុំទឹកល្អក់ ស្រុកព្រៃនប់

០២១២: ឃុំទឹកថ្លា ស្រុកព្រៃនប់

០២១៣: ឃុំទួលទទឹង ស្រុកព្រៃនប់

# II. ទិដ្ឋភាពរួមនៃការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ

## ២.១ រចនាសម្ព័ន្ធស្ថាប័ន

មានការសម្រេចបានវឌ្ឍនភាពយ៉ាងល្អក្នុងការបង្កើតក្របខ័ណ្ឌស្ថាប័នសម្រាប់សម្របសម្រួលការកសាងផែនការប្រែប្រួលអាកាសធាតុ និងវិធានការនយោបាយឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (UNFCCC) តាំងពីឆ្នាំ ១៩៩៦ មក។ គណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ ដែលមានអាណត្តិ រៀបចំ សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ NCCC គឺជាគណៈកម្មការធិការសម្របសម្រួលជាន់ខ្ពស់អន្តរក្រសួង ដែលមាននាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស និងរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធានអចិន្ត្រៃយ៍។ គណៈកម្មាធិការនេះមានសមាជិកជាតំណាងមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធចំនួន ២០ ដែលតំណាងឲ្យក្រសួងនានា ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF), ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ( MIME) និងក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ដែលមាននាទីជាអនុប្រធាន។ ដើម្បីបំពេញអាណត្តិរបស់ខ្លួន គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) បានទទួលសេវាគាំទ្រពីនាយកដ្ឋាន ប្រែប្រួលអាកាសធាតុ (CDD) ដែលបានបង្កើតឡើងនៅក្រោមក្រសួងបរិស្ថាន និងក្រុមការងារបច្ចេកទេស (CCTT) ដែលបង្កើតឡើងដោយមន្ត្រីបច្ចេកទេសមកពីក្រសួងពាក់ព័ន្ធ។ អនុក្រឹត្យមួយស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) (ខែមេសា ឆ្នាំ២០០៦) ចែងបញ្ជាក់ពីតួនាទីរបស់ NCCC ដូចតទៅ៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តិ ផែនការ និងកម្មវិធីប្រែប្រួលអាកាសធាតុ ដែលរួមទាំងផែនការសកម្មភាពជាតិកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់(GHG) និងផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ដាក់ជូនទៅរាជរដ្ឋាភិបាលកម្ពុជាសម្រាប់សុំការពិនិត្យ និងអនុម័ត
- លើកកំពស់ និងលើកទឹកចិត្តឲ្យមានការចូលរួមទូលំទូលាយនៃអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងការអភិវឌ្ឍ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តិ ផែនការ និងកម្មវិធីប្រែប្រួលអាកាសធាតុ ដើម្បីធានាឲ្យមានសង្គតិភាពជាមួយគោលបំណង និងអាទិភាពនានានៃការអភិវឌ្ឍជាតិ
- លើកកំពស់ និងលើកទឹកចិត្តឲ្យមានសមាហរណកម្មកង្វល់អំពីការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តិ ផែនការ និងកម្មវិធីប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធ
- កៀងគរធនធាន ជាពិសេស ជំនួយឥតសំណង សម្រាប់ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងកម្មវិធីប្រែប្រួលអាកាសធាតុទាំងនេះ

- លើកកំពស់ការផ្ទេរបច្ចេកវិទ្យាសមស្រប បច្ចេកវិទ្យាកកើតឡើងវិញ និងការអភិរក្ស និងបង្កើនស្តុកកាបូន
- កំណត់ជំហរនិងយុទ្ធសាស្ត្រជាតិសម្រាប់ការចូលរួមនៅក្នុងការចរចាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- ពិនិត្យនិងអនុម័តលើរបាយការណ៍ជាតិដែល UNFCCC តម្រូវឲ្យរៀបចំ
- សម្របសម្រួលសកម្មភាពនានាដែលទាក់ទងនឹងការអនុវត្ត UNFCCC ពិធីសារនៃអនុសញ្ញានេះ និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតស្តីពីការប្រែប្រួលអាកាសធាតុ ដែលកម្ពុជាគឺជាភាគីសមាជិក
- គ្រប់គ្រង និងសម្របសម្រួលយន្តការអភិវឌ្ឍន៍ស្អាតនៃពិធីសារក្យូតូនៅកម្ពុជា
- រាយការណ៍ទៅរាជរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាប្រែប្រួលអាកាសធាតុ ស្ថានភាពនៃការអនុវត្ត UNFCCC និងដំណើរការចរចាអន្តរជាតិ
- លើកកំពស់ការអប់រំ បង្កើនការយល់ដឹង ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ សម្រាប់សាធារណជនទូទៅ
- ចូលរួមនៅក្នុងសន្និសីទ និងសិក្ខាសាលាជាតិ តំបន់ និងអន្តរជាតិ ស្តីពីបញ្ហាដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ
- សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តគម្រោង កម្មវិធី និងសកម្មភាពស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា
- ពិនិត្យ និងអនុម័តលើផែនការការងារ និងរបាយការណ៍នៃក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ (CCTT) ដែលត្រូវបង្កើតឡើងអនុលោមតាមមាត្រា ៤ នៃអនុក្រឹត្យនេះ
- លើកកំពស់កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យប្រែប្រួលអាកាសធាតុ។

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុនៅតែខ្វះសមត្ថភាពបច្ចេកទេស គោលការណ៍ណែនាំ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងធនធាន សម្រាប់ការសម្របសម្រួល និងការអនុវត្តគម្រោង និងកម្មវិធីប្រែប្រួលអាកាសធាតុឲ្យមានប្រសិទ្ធភាព និងពឹងផ្អែកជាខ្លាំងលើធនធានមូលនិធិពីប្រភពខាងក្រៅ។ ទោះជាយ៉ាងណាក៏ដោយ សមត្ថភាព និងការកៀរគរធនធានបានកែលម្អជាបណ្តើរៗ តាមរយៈការបង្កើតកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ដែលជាកិច្ចផ្តួចផ្តើមពហុម្ចាស់ជំនួយ ទទួលមូលនិធិពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក់ (DANIDA) និងគណៈកម្មការអឺរ៉ុប (EC)។ គោលបំណងអភិវឌ្ឍន៍នៃកម្មវិធី CCCA គឺៈ "សកម្មភាពប្រែប្រួលអាកាសធាតុនៅកម្ពុជា គឺជារបស់ជាតិ ដឹកនាំដោយស្ថាប័នជាតិ និងបន្សុីជាមួយអាទិភាពអភិវឌ្ឍន៍របស់កម្ពុជា និងត្រូវបានសម្របសម្រួល និងអនុវត្តប្រកបដោយប្រសិទ្ធភាព"។ អនាគតនៃកម្មវិធី CCCA និងមូលនិធិប្រែប្រួលអាកាសធាតុនៃកម្មវិធីនេះ នៅពុំទាន់ច្បាស់លាស់នៅឡើយទេ ពោលគឺ ថាតើនឹងបន្តតាមទម្រង់ដដែលនៃដំណាក់កាលទីមួយក្នុងកម្មវិធីនេះ ឬបម្លែងទៅជាយន្តការអចិន្ត្រៃយ៍សម្រាប់កៀងគរនិងវិភាជន៍មូលនិធិ ឬយ៉ាងណា។

## ២.២ ដំណើរការកសាងផែនការ

ការកសាងផែនការប្រែប្រួលអាកាសធាតុ មិនត្រូវបានចាត់ទុកជាការងារកសាងផែនការដាច់ដោយឡែក

ឡើយ ប៉ុន្តែបានពង្រឹងជាបន្ថែម និងបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងផែនការអភិវឌ្ឍន៍តាមវិស័យដែលពាក់ព័ន្ធទាំងអស់ ដោយស្នើឲ្យមានការអនុម័តពីរដ្ឋមន្ត្រីនិងដាក់ជូនទៅក្រសួងផែនការដើម្បីបញ្ចូលទៅក្នុងNSDP។ ការអនុម័តលើផែនការទាំងនេះ ក៏ដូចជា កម្មវិធីវិនិយោគសាធារណៈ (PIP) ជាក់លាក់ ត្រូវបានសម្របសម្រួលដោយក្រសួងផែនការ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។ តួនាទីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺត្រូវធ្វើការចរចាជាមួយក្រសួងពាក់ព័ន្ធ លើសំណើថវិកាសម្រាប់សកម្មភាពដែលគ្រោងទុករបស់ខ្លួនដែលនឹងត្រូវរួមបញ្ចូលទៅក្នុងច្បាប់ថវិកា ដែលត្រូវអនុម័តដោយសភាជាតិប្រចាំឆ្នាំ។

ដំណើរការកសាងផែនការប្រែប្រួលអាកាសធាតុស្ទើរតែអនុវត្តទាំងស្រុងតាមទម្លាប់អនុវត្តនិងគោលការណ៍ណែនាំរបស់ក្រសួងផែនការ និងគណៈរដ្ឋមន្ត្រី។ ភាពខុសគ្នាគឺថា ការកសាងផែនការប្រែប្រួលអាកាសធាតុទាមទារឲ្យមានការយល់ដឹងទូលំទូលាយអំពីផលប៉ះពាល់ និងហានិភ័យនៃការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើការទស្សន៍ទាយណាមួយដែលបានធ្វើឡើង និងការគិតគូរអំពីវិធានការគោលនយោបាយដែលមានប្រសិទ្ធភាពលើការចំណាយសម្រាប់ការឆ្លើយតប។ ទោះបី IPCC និងអង្គការដទៃទៀតជាច្រើនបានរៀបចំ ឧបករណ៍ និងគោលការណ៍ណែនាំសម្រាប់កសាងផែនការក៏ដោយ ការគិតគូរអំពីវិធានការឆ្លើយតបសមស្របនៅតែជាការប្រឈមនៅឡើយដោយសារតែភាពមិនប្រាកដប្រជា ដែលទាក់ទងនឹងការទស្សន៍ទាយអំពីការប្រែប្រួលអាកាសធាតុ និងការលំបាកនៅក្នុងការធ្វើម៉ូដែលហានិភ័យ និងផលប៉ះពាល់ និងម៉្យាងទៀត ដោយសារស្ថានភាពសេដ្ឋកិច្ចសង្គម នៅក្នុងសហគមន៍ និងកង្វះសមត្ថភាពបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។ គំរូ ឧបករណ៍ និងគោលការណ៍ណែនាំត្រូវបាននាយកដ្ឋានប្រែប្រួលអាកាសធាតុបង្កើតឡើង ដោយមានជំនួយបច្ចេកទេសពី CCCA។ គោលការណ៍ទាំងនោះបានផ្អែកលើនីតិវិធីរបស់រដ្ឋាភិបាល និងទម្លាប់ល្អជាអន្តរជាតិ អំពីការកសាងផែនការប្រែប្រួលអាកាសធាតុ ប៉ុន្តែនៅត្រូវកែសម្រួលបន្ថែមទៀត។ ប្រភពមូលនិធិដែលមានក្នុងកម្រិតកំណត់ និងភាពប្រកួតប្រជែងនៃអាទិភាពអភិវឌ្ឍន៍គឺជាឧបសគ្គបន្ថែមទៀតចំពោះការបញ្ជ្រាបការប្រែប្រួលអាកាសធាតុឲ្យមានប្រសិទ្ធភាពនៅថ្នាក់ជាតិ។

ទាក់ទងនឹងដំណើរការអនុម័ត គេនៅពុំទាន់ច្បាស់ទេថា តើយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យ និងផែនការសកម្មភាព(ឬ PIP)ត្រូវសុំការគាំទ្រពី NCCC ឬយ៉ាងណា? មុននឹងដាក់ជូនទៅក្រសួងផែនការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អ្វីដែលច្បាស់លាស់នៅក្នុងដំណាក់កាលនេះគឺ តួនាទីសម្របសម្រួលដែល NCCC អាចអនុវត្ត ដែលរាប់បញ្ចូលការលើកកំពស់ការអភិវឌ្ឍសមត្ថភាព និងបង្កើនការយល់ដឹង ការផ្តល់គោលការណ៍ណែនាំ និងការវាយតម្លៃហានិភ័យ/ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងសក្តានុពលនៃការកាត់បន្ថយ និងការកៀរគរមូលនិធិគាំទ្រពីប្រភពខុសៗគ្នា។ ការងារដំបូងត្រូវបានអនុវត្តក្រោមរូបភាពជាការរៀបចំរបាយការណ៍ជាតិទៅ UNFCCC និងការបង្កើតផែនការសកម្មភាពជាតិបន្សុំានឹងការប្រែប្រួលអាកាសធាតុ(NAPA)នៅឆ្នាំ ២០០៦ ដែលដំណើរការជាឧបករណ៍ដំបូងសម្រាប់កសាងផែនការ និងការវាយតម្លៃ និងផ្សំដោយក្របខ័ណ្ឌគោលនយោបាយសម្រាប់វិធានការឆ្លើយតបនៅក្នុងការបន្សុំាក្នុងវិស័យអាទិភាពចំនួនបួនៈ កសិកម្ម ធនធានទឹក សុខភាព និងតំបន់ឆ្នេរ។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ត្រូវបានរៀបចំរួចរាល់ និងអនុម័តដោយនាយករដ្ឋមន្ត្រីកម្ពុជា រួមជាមួយផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យសម្រាប់ក្រសួងចំនួនដប់ ពោលគឺ ក្រសួងបរិស្ថាន (MOE) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF) ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME),

ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្រសួងសុខាភិបាល (MOH) គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្រសួងអប់រំ យុវជន និងកីឡា (MOEYS) និងក្រសួងកិច្ចការនារី(MOWA)។ ក្រសួងពាក់ព័ន្ធបច្ចុប្បន្នស្ថិតក្នុងដំណើរការកសាងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ (CCAP) ដោយផ្អែកលើគោលការណ៍ណែនាំពីគណៈរដ្ឋមន្ត្រី។ ផែនការ CCAPs ចែងអំពីតារាងសកម្មភាពអាទិភាពសម្រាប់រយៈពេលប្រាំឆ្នាំ ស្របជាមួយក្របខ័ណ្ឌពេលវេលានៃNSDP ២០១៤-២០១៨។ រួមជាមួយគ្នា CCCSP, SCCSPs និងCCAPs ផ្តល់នូវក្របខ័ណ្ឌទូលំទូលាយ សម្រាប់ការរួមបញ្ចូលគម្រោង និងកម្មវិធីប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ស្របជាមួយនីតិវិធីរបស់ CCCA រាជរដ្ឋាភិបាលកម្ពុជា ក្រោមកិច្ចសហការជាមួយធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បានបង្កើត"កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ"(SPCR)ដែលមានគោលដៅគាំទ្រដល់ការវិនិយោគ និងសកម្មភាពកសាងសមត្ថភាពសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ ផែនការ និងគម្រោងអភិវឌ្ឍន៍។ កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) ជំហានទី ១ ត្រូវបានបង្កើតឡើង តាមរយៈជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក និង UNDP និងបានចូលជាធរមាននៅខែ មករា ឆ្នាំ ២០១១ ជាមួយជំនួយឥតសំណង ១,៥លានដុល្លាអាមេរិក ពីមូលនិធិវិនិយោគអាកាសធាតុ(CIF)។ គោលបំណងបឋមនៃកម្មវិធីនេះ គឺរៀបចំការងារជាមូលដ្ឋានសម្រាប់ការវិនិយោគនៅដំណាក់កាលទីពីរ នៅក្រោម SPCR ដែលត្រូវបានរៀបចំឡើងជាប្រាំសមាសភាគ។ ការកសាងផែនការ PPCR និង SPCR បានផ្អែកលើបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកស្វែងរកការណ៍ពិត ដែលបានធ្វើឡើងដើម្បីកំណត់អត្តសញ្ញាណគម្រោងភាពធន់នឹងអាកាសធាតុដែលមានសក្តានុពល ក្រោមការពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដទៃទៀត។ ធនាគារអភិវឌ្ឍន៍អាស៊ីបានទទួលស្គាល់អំពីតួនាទីរបស់ NCCC និង CCTT នៅក្នុងដំណើរការពិគ្រោះយោបល់ និងក្នុងគោលបំណងអនុម័តគាំទ្រ។ ក្រោយការអនុម័តគាំទ្រពី NCCC ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើរតួជាសំខាន់លើការចរចាជាមួយម្ចាស់ជំនួយអំពីការផ្តល់មូលនិធិសម្រាប់គម្រោង PPCR និងនៅក្នុងការធ្វើសេចក្តីសម្រេចអំពីសំណុំរឿងហិរញ្ញប្បទានគម្រោង។ សំណើនានានៅក្រោមPPCRដំណាក់កាលទីពីរត្រូវបានរៀបចំឡើង និងអនុម័តដោយ CIF នៅខែមិថុនា ឆ្នាំ ២០១១ ជាមួយថវិកាសរុប ៨៦ លានដុល្លាអាមេរិក។ ឥឡូវនេះ SPCR កំពុងស្ថិតក្នុងការអនុវត្តដោយអាចមានមូលនិធិគាំទ្រជិត ៤០០លានដុល្លាអាមេរិកសម្រាប់គម្រោងវិនិយោគ ភាគច្រើនលើវិស័យធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្ម។ មានការយល់ឃើញថាដំណើរការកសាងផែនការ និងការលើកថវិកាសម្រាប់ការងារប្រែប្រួលអាកាសធាតុ នឹងវិវត្តជាបណ្តើរៗ និងអាចត្រូវការពេលវេលាមួយរយៈ មុននឹងអាចក្លាយជាកិច្ចការធម្មតារបស់អង្គភាពនានារបស់រដ្ឋាភិបាលនៅលំដាប់ថ្នាក់ខុសៗគ្នា។ ជោគជ័យនៃដំណើរការនេះ អាស្រ័យលើការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល/ហិរញ្ញវត្ថុដែលមានការវិវត្តនៅថ្នាក់ជាតិ ក៏ដូចជា ការសម្របសម្រួលរវាងផ្នែកខុសៗគ្នានៃកិច្ចការ ក្នុងចំណោមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF), ក្រសួងផែនការ(MOP), NCCC/MOE, ក្រសួងពាក់ព័ន្ធ និងគណៈកម្មាធិការជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(NCDD) នៅថ្នាក់ក្រោមជាតិផងដែរ។ ក្រោយពេលបង្កើតក្នុងពេលថ្មីៗនេះនៃរាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា រចនាសម្ព័ន្ធស្ថាប័នថ្មីមួយនៃ MEF ត្រូវបានអនុម័តដោយអនុក្រឹត្យ (ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣) ដែលនាំឲ្យក្រសួងនេះមានអគ្គនាយកដ្ឋានចំនួនសរុប ១២

ក្នុងនោះអគ្គនាយកដ្ឋានមួយ អាចពាក់ព័ន្ធនឹងហិរញ្ញប្បទាននៅថ្នាក់ក្រោមជាតិសម្រាប់បញ្ហាប្រែប្រួលអាកាសធាតុ ពោលគឺ អគ្គនាយកដ្ឋានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រសួងដ៏ទៃទៀតក៏អាចកែសម្រួលរចនាសម្ព័ន្ធផងដែរ។ ប៉ុន្តែប្រការសំខាន់បំផុតគឺត្រូវជានាថា សមត្ថភាពនៃការធ្វើវិភាជន៍មូលនិធិរបស់រដ្ឋាភិបាលដោយមានសង្គតិភាព និងនិរន្តរភាព ពីសហគមន៍ម្ចាស់ជំនួយអន្តរជាតិ ដល់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការផ្ទេរដោយរលូននូវមុខងារពីក្រសួងនានានៅថ្នាក់ជាតិ មករដ្ឋបាលថ្នាក់ក្រោមជាតិ និងយន្តការសម្របសម្រួលការងារប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ ត្រូវបានអនុម័ត ដែលជាផ្នែកមួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D)។

## III. ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ

### ៣.១ រចនាសម្ព័ន្ធស្ថាប័ន

ការកសាងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិក្នុងពេលបច្ចុប្បន្ននេះ បានធ្វើឡើងដោយអង្គភាពចំនួនពីរៈ មន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត ដែលផ្សារភ្ជាប់ជាមួយក្រសួងសាមីនៅថ្នាក់កណ្តាល និងក្រុមប្រឹក្សាខេត្ត ស្រុក/ក្រុង និង ឃុំ/សង្កាត់ ដែលផ្សារភ្ជាប់ជាមួយក្រសួងមហាផ្ទៃ (MOI) និង NCDD។ បច្ចុប្បន្ននេះ មន្ទីរខេត្តអនុវត្តតាមដំណើរការកសាងផែនការ និងនីតិវិធី តាមការណែនាំរបស់ក្រសួងនៅថ្នាក់កណ្តាល និងអាជ្ញាធរខេត្ត ចំណែកក្រុមប្រឹក្សាខេត្ត ស្រុក និងឃុំ អនុវត្តតាមដំណើរការកសាងផែនការដែលមានចែងនៅក្នុងច្បាប់សរីរាង្គ (ខែ ឧសភា ឆ្នាំ ២០០៨) ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, "ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ស្រុកនិងខណ្ឌ" (ខែ ឧសភា ឆ្នាំ ២០០៨), អនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរំកិលបីឆ្នាំ សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ខែធ្នូ ឆ្នាំ ២០០៩), និងសេចក្តីប្រកាសរួមស្តីពីផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគបីឆ្នាំរំកិល សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ (ខែធ្នូ ២០១០)។

ជាផ្នែកមួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ D&D និងផ្អែកតាមមាត្រា ២០០០ នៃច្បាប់សរីរាង្គ មន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្តទំនងជានឹងត្រូវផ្ទេរមកក្របខ័ណ្ឌរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះ នីតិវិធីកសាងផែនការរបស់ពួកគេ ត្រូវតែអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ណែនាំរបស់ NCDD ចំណែកក្រសួងពាក់ព័ន្ធនៅថ្នាក់កណ្តាលផ្តល់ការណែនាំខាងគោលនយោបាយ។ អនុក្រឹត្យមួយស្តីពីដំណើរការនៃការផ្ទេរមុខងារ និងធនធានមករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តនៅឆ្នាំ ២០១២ ដែលចែងអំពីដំណើរការទូទៅ និងពេលវេលាសម្រាប់ការផ្ទេរមុខងារ និងធនធានពីក្រសួង និងស្ថាប័ននានាមករដ្ឋបាលមូលដ្ឋាន អនុលោមតាមច្បាប់សរីរាង្គ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (២០០១)។ ទោះជាយ៉ាងណាក៏ដោយ មានការរីកចម្រើនត្រឹមតិចតួចប៉ុណ្ណោះដែលសម្រេចបាន ក្នុងន័យនេះ ដែលប្រហែលជាដោយសារខ្វះភាពច្បាស់លាស់អំពីការផ្ទេរធនធាន ក៏ដូចជា ភាពមិនស៊ីសង្វាក់គ្នារវាងច្បាប់សរីរាង្គ និងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ[1] (ADB ២០១១)។

[1] ការលើកថវិកា ការអនុម័ត និងផលចំណូលស្ថិតក្រោមអំណាចត្រួតត្រាដោយ MEF នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សេចក្តីព្រាងច្បាប់មួយស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់បានអនុម័តនៅឡើយទេ ដែលអាចកែលម្អការវិភាជន៍ធនធានសម្រាប់គម្រោងនៅមូលដ្ឋាន (ADB ២០១១) ។

ច្បាប់សរីរាង្គចែងអំពីការបង្កើតក្របខ័ណ្ឌស្ថាប័នថ្នាក់ក្រោមជាតិសម្រាប់កសាងផែនការអភិវឌ្ឍន៍ ដែលរួមមាន NCDD, ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលរួមមាន ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក/ខណ្ឌ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាល និងក្រុមប្រឹក្សាឃុំ/សង្កាត់។

### ក. គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យមួយនៅខែ ធ្នូ ឆ្នាំ ២០០៨ អនុលោមតាមច្បាប់សរីរាង្គ។ NCDD មានសមាជិក ១៦រូប ដែលតែងតាំងដោយក្រសួងសំខាន់ៗ និងមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន។ ក្រសួងបរិស្ថានមិនបានរួមបញ្ចូលជាសមាជិកឡើយ។ តួនាទីសំខាន់របស់ NCDD គឺបង្កើត និងអនុវត្តកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អនុលោមតាមច្បាប់សរីរាង្គ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (២០០១) ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (PFS), ក៏ដូចជាធ្វើការពិគ្រោះយោបល់ និងសម្របសម្រួលជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធទាំងអស់ផងដែរ ទាក់ទងជាមួយការផ្ទេរមុខងារ និងការទទួលខុសត្រូវ ទៅឲ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលរួមមាន៖

- ការផ្ទេរធនធាន ដែលរួមទាំងផលចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាព សម្រាប់គ្រប់គ្រង និងបំពេញមុខងាររៀងៗខ្លួន
- ផ្តល់ការកសាងសមត្ថភាព និងសិទ្ធិអំណាច ដើម្បីទទួលបានធនធាន ដែលចាំបាច់សម្រាប់គ្រប់គ្រង និងបំពេញមុខងារនីមួយៗ ដែលរួមមាន ផលចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាព
- ការផ្តល់អំណាច និងករណីយកិច្ចគ្រប់គ្រង និងអនុវត្តមុខងាររៀងៗខ្លួនទាំងអស់ ស្របជាមួយស្វ័យភាពនៅមូលដ្ឋាន និងគណនេយ្យភាព ជាអតិបរមានៅមូលដ្ឋាន។

បន្ថែមលើនេះ NCDD បានបង្កើតអនុគណៈកម្មការចំនួនបី តាមរយៈអនុក្រឹត្យមួយ (ខែ មករា ឆ្នាំ២០០៩), ពោលគឺ គណៈកម្មការទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ និងសារពើពន្ធ និងអនុគណៈកម្មការស្តីពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ គួរកត់សំគាល់ថា ការផ្តល់មូលនិធិមករដ្ឋបាលស្រុក និងឃុំ ត្រូវបានគ្រប់គ្រងតាមរយៈ NCDD, ទោះបីសមាមាត្រមួយផ្នែកធំនៃមូលនិធិត្រូវបានផ្តោតលើការចំណាយចរន្តក៏ដោយ។

### ខ. ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

ក្រុមប្រឹក្សាក្រុង ខេត្ត ស្រុក និងខណ្ឌ ត្រូវបានបង្កើតដោយការបោះឆ្នោតមិនផ្ទាល់ សម្រាប់អណត្តិរយៈពេលប្រាំឆ្នាំ។ ក្រុមប្រឹក្សាទាំងនេះមានភារៈទទួលខុសត្រូវលើការបង្កើត និងអនុម័តលើផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (DP5) ដែលត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ដែលជាផ្នែកមួយនៃកម្មវិធីវិនិយោគរំកិលបីឆ្នាំ (IP3); ការពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្ត DP5 និង IP3, ការអនុម័តថវិកា និងផែនការចំណាយ, និងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិ។ គណៈអភិបាលត្រូវបានតែងតាំងដោយនាយករដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃ ដើម្បីគាំទ្រដល់ក្រុមប្រឹក្សានានាក្នុងការអនុវត្តមុខងាររបស់ខ្លួន ដែលរួមទាំងការអនុវត្ត DP5 និង IP3, និងផ្តល់ការណែនាំ។ ប្រៀបធៀប

នឹងរចនាសម្ព័ន្ធនៅថ្នាក់ជាតិ មុខងារនានារបស់ក្រុមប្រឹក្សា មានលក្ខណៈប្រហែលគ្នានឹងរដ្ឋសភា ចំណែកគណៈ-អភិបាលមាននាទីជាស្ថាប័នប្រតិបត្តិ។

### គ. ក្រុមប្រឹក្សាឃុំ

ក្រុមប្រឹក្សាឃុំត្រូវបានបង្កើតនៅក្នុងឃុំនីមួយៗ តាមរយៈការបោះឆ្នោតផ្ទាល់រៀងរាល់ប្រាំឆ្នាំម្តង។ មិនដូចក្រុមប្រឹក្សាខេត្តនិងស្រុកឡើយ ក្រុមប្រឹក្សាឃុំមានភារៈទទួលខុសត្រូវក្នុងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (CDP5) និងកម្មវិធីវិនិយោគរំកិលរយៈពេលបីឆ្នាំ (CIP3) ដែលត្រូវរួមបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ស្រុក និងកម្មវិធីវិនិយោគរំកិលថ្នាក់ស្រុកសម្រាប់រយៈពេលបីឆ្នាំ។

## ៣.២ នីតិវិធី និងដំណើរការសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ

នីតិវិធី និងដំណើរការសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ថ្នាក់ខេត្ត និងស្រុកសម្រាប់រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគរំកិលរយៈពេលបីឆ្នាំ មានចែងនៅក្នុងអនុក្រឹត្យខែធ្នូ ឆ្នាំ ២០០៩ និងនៅក្នុងសេចក្តីប្រកាសរួមរវាងក្រសួងមហាផ្ទៃ និងក្រសួងផែនការ ខែ ធ្នូ ឆ្នាំ ២០១០។ ក្រុមការងារកសាងផែនការ (PWG) សម្រាប់ DP5 និង IP3 មានសមាសភាពជាតំណាងមកពីមន្ទីរពាក់ព័ន្ធទាំងអស់នៅថ្នាក់ខេត្ត និងមានអភិបាលខេត្តជាប្រធាន។ ប្រធានមន្ទីរផែនការខេត្ត គឺជាសមាជិកអចិន្ត្រៃយ៍។ ក្រុមការងារកសាងផែនការមានភារៈទទួលខុសត្រូវដោយផ្ទាល់លើការរៀបចំផែនការនានា ដែលរួមទាំងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធផងដែរ។

ការកសាងផែនការ DP5 នៅថ្នាក់ខេត្ត គឺជាដំណើរការដែលមានបួនជំហានៈ

- ជំហានទី ១: ការកសាងផែនការការងារ និងកាលវិភាគសម្រាប់ការអនុវត្ត ដែលរួមទាំង ការប្រមូលឯកសារចាំបាច់
- ជំហានទី ២: ការផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់នូវព័ត៌មានស្តីពីការរៀបចំ DP5
- ជំហានទី៣: ការរៀបចំសេចក្តីព្រាង DP5 ដោយផ្អែកលើគោលការណែនាំគោលនយោបាយ និងនីតិវិធីដែលមានចែងនៅក្នុងប្រកាសរួម។ សកម្មភាពចំបងៗ រួមមាន ការវិភាគស្ថានភាព និងការកំណត់អត្តសញ្ញាណការប្រឈម (លក្ខខណ្ឌសេដ្ឋកិច្ច-សង្គម ការប្រើប្រាស់ដី និងការគ្រប់គ្រងបរិស្ថាន ស្ថានភាព នៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ និងរដ្ឋបាល និងសន្តិសុខ) ការរៀបចំក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ (M&E) ក៏ដូចជា ការចាត់ចែងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ គណៈអភិបាល និងគណៈកម្មការសម្របសម្រួលបច្ចេកទេសផងដែរ។ ជំហានទី ៣ ផ្តល់លទ្ធភាពសម្រាប់ការរួមបញ្ចូលនូវការវិភាគ និងវិធានការបន្សាំទៅ នឹងការប្រែប្រួលអាកាសធាតុទៅក្នុង DP5។ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរពាក់ព័ន្ធនានា អាចពាក់ព័ន្ធនៅក្នុងការកំណត់គម្រោង ឬកម្មវិធីជាក់លាក់ណាខ្លះដែលគួរបញ្ចូលនៅក្នុង IP3។
- ជំហានទី ៤: ការអនុម័តគាំទ្រ DP5 ដែលការពិនិត្យ និងការកែសម្រួលធ្វើឡើងតាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាស្រុក/ខណ្ឌ មុនពេលអនុម័តគាំទ្រដោយក្រុមប្រឹក្សារាជធានី ឬខេត្ត, ការប្រកាសអនុវត្ត DP5, និងការពិនិត្យតាមដាន និងវាយតម្លៃ។

ផែនការ DP5 នៅថ្នាក់ខេត្ត ត្រូវរៀបចំឡើង តាមរយៈការពិគ្រោះយោបល់ទូលំទូលាយជាមួយអ្នកពាក់ព័ន្ធនានា ដូចតទៅ៖

- ក្រុមប្រឹក្សារាជធានី/ខេត្ត
- ក្រុមប្រឹក្សាក្រុង/ស្រុក/ខណ្ឌ
- គណៈកម្មការសម្របសម្រួលបច្ចេកទេស និងគណៈកម្មការដទៃទៀតនៅក្រោមក្រុមប្រឹក្សាស្រុក
- គណៈអភិបាលខេត្ត ក្រុង ឬស្រុក
- ក្រុមការងារកសាងផែនការថ្នាក់ខេត្ត ក្រុង/ស្រុក
- ការិយាល័យ ឬផ្នែកអភិបាលស្រុក
- ការិយាល័យ ឬផ្នែកក្រសួងពាក់ព័ន្ធនានានៅថ្នាក់ស្រុក និងខេត្ត
- ក្រុមប្រឹក្សាឃុំ
- សហគមន៍
- សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន។

ប្រការ ១៧ នៃប្រកាសរួមចែងថា ដំណើរការអនុម័តលើ DP5 ត្រូវការឲ្យមានការពាក់ព័ន្ធនៃ NCDD, ក្រសួងមហាផ្ទៃនិងក្រសួងពាក់ព័ន្ធដទៃទៀត។ ក្រោយការអនុម័តគាំទ្រដោយក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ត្រូវដាក់ជូនសេចក្តីព្រាង DP5 ទៅអភិបាលរាជធានី/ខេត្ត ដើម្បីកែសម្រួល និងដាក់ជូនជាបន្តទៅលេខាធិការដ្ឋាន NCDD។ លេខាធិការដ្ឋាន NCDD ត្រូវចម្លងជូន DP5 ទៅក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសម្របសម្រួលដំណើរការពិនិត្យ និងការពិគ្រោះយោបល់ ជាមួយក្រសួងទាំងបីនេះ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីធានាថា ផែនការនោះស្របគ្នាជាមួយគោលនយោបាយ ច្បាប់ ប្រកាសនានា និងបទប្បញ្ញត្តិនានារបស់រដ្ឋាភិបាល។ ក្រោយការពិគ្រោះយោបល់ លេខាធិការដ្ឋាន NCDD ត្រូវដាក់ជូនរបាយការណ៍សង្ខេប និងអនុសាសន៍ទៅក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងអនុម័ត ដែលត្រូវធ្វើឡើងនៅក្នុងរយៈពេល ៣០ថ្ងៃ គិតពីថ្ងៃដាក់ជូនដោយអភិបាលរាជធានី/ខេត្ត។ អំឡុងពេលនេះត្រូវតែជាការចាត់ចែងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា ដែលរួមទាំងបំភ្លឺរាល់បញ្ហាដែលនៅមិនទាន់ដាច់ស្រេច ជាមួយអភិបាលរាជធានី/ខេត្ត។ នៅក្នុងករណីគ្មានការឯកភាពលើសេចក្តីព្រាងនេះទេ ក្រសួងមហាផ្ទៃត្រូវជូនដំណឹង និងស្នើសុំ NCDD ឲ្យសម្របសម្រួលរកដំណោះស្រាយ។ ក្នុងករណីគ្មានការឆ្លើយតបពីក្រសួងផែនការនៅក្នុងរយៈពេល ៣០ថ្ងៃ ត្រូវសន្មត់ថា DP5 បានទទួលការអនុម័តគាំទ្រ។ ជំហានបន្ទាប់គឺត្រូវបោះពុម្ពផ្សាយ និងចែកចាយឯកសារផែនការ DP5។ ផែនការ DP5 ផ្តល់ជាក្របខ័ណ្ឌអភិវឌ្ឍន៍ទូទៅ ដែលចែកចេញជា ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រ សម្រាប់ដោះស្រាយបញ្ហាបួនជំពូក៖ ១) បញ្ហាសេដ្ឋកិច្ច ២) បញ្ហាសង្គម ៣) ការប្រើប្រាស់ដី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុ និង ៤) រដ្ឋបាលនិងសន្តិសុខ (សូមអានឧទាហរណ៍ក្នុងប្រអប់ ១)។ ដោយសារការប្រែប្រួលអាកាសធាតុគឺជាបញ្ហាអន្តរវិស័យ គម្រោងប្រែប្រួលអាកាសធាតុ អាចបញ្ជ្រាបទៅក្នុងជំពូក

**ប្រអប់ ១៖ គោលដៅ DP5 ស្តីពីការប្រើប្រាស់ដី បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅកោះកុង**

**ការគ្រប់គ្រងដីធ្លី និងសំណង់**

- ការបង្កើតសម្បទានដីសង្គមកិច្ចសម្រាប់ជលរដ្ឋក្រីក្រ យោធិនពិការ និងគ្រួសារគ្មានដីធ្លី
- បង្កើតផែនការមេស្តីពីការប្រើបាស់ដី និងកសាងផែនការប្រើប្រាស់ដី អនុលោមតាមតម្រូវការអភិវឌ្ឍន៍
- បង្កើនការយល់ដឹងអំពីច្បាស់ភូមិបាល និងសំណង់
- លុបបំបាត់ការទន្ទ្រានយកដីដោយល្មើសច្បាប់ និងការកំណត់ព្រំដែនដីរដ្ឋ

**ព្រៃឈើ**

- លើកកំពស់ការប្រើប្រាស់ធនធានព្រៃឈើឲ្យមាននិរន្តរភាព

**បរិស្ថាន**

- កែលម្អការគ្រប់គ្រងសំណល់រឹង លូទឹកសំអុយ និងការពង្រឹងសហគមន៍តំបន់ការពារធម្មជាតិ

**គ្រោះធម្មជាតិ**

- ការពង្រឹងការត្រៀមបង្ការ ការទប់ស្កាត់ និងវិធានការសង្គ្រោះ ក្នុងការឆ្លើយតបនឹងហានិភ័យគ្រោះមហន្តរាយធម្មជាតិ

**ការប្រេប្រួលអាកាសធាតុ**

- លើកកំពស់វិធានការឆ្លើយតប និងបន្សុំាំនឹងការប្រែប្រួលអាកាសធាតុ។

១, ២, ៣ ដែលអាចពាក់ព័ន្ធជាមួយវិស័យជាច្រើន ដូចជា ធនធានទឹក កសិកម្ម ការប្រើប្រាស់ដី ព្រៃឈើ បរិស្ថាន និងវិស័យសុខភាព។ ប្រអប់១ ផ្តល់សេចក្តីអធិប្បាយអំពីសមត្ថភាពរបស់ក្រុមប្រឹក្សាខេត្តកោះកុង ក្នុងការរួមបញ្ចូលគោលដៅដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការ DP5, ទោះបីសមិទ្ធផលរបស់ពួកគេ អាស្រ័យលើកត្តានានាដទៃទៀត ដូចជា វត្តមានមូលនិធិ និងសមត្ថភាពរបស់គណៈអភិបាលខេត្ត គណៈអភិបាលស្រុក មន្ទីរពាក់ព័ន្ធនានានៅថ្នាក់ខេត្តនិងក្រុមប្រឹក្សាឃុំក៏ដោយ។ បញ្ហានេះនឹងមានចែងពិស្តារបន្ថែមក្នុងផ្នែកទី IV ។

ផែនការ DP5 នៅថ្នាក់ស្រុកត្រូវអនុម័តដោយអភិបាលខេត្ត នៅក្នុងរយៈពេល ៣០ថ្ងៃ (មាត្រា 18) ក្រោយការអនុម័តគាំទ្រដោយក្រុមប្រឹក្សាស្រុក និងការដាក់ជូនសេចក្តីព្រាងដោយអភិបាលស្រុក។ នៅក្នុងករណីគ្មានការឯកភាព អភិបាលខេត្តត្រូវជូនដំណឹង និងស្នើសុំទៅលេខាធិការដ្ឋាន NCDD ដើម្បីសម្របសម្រួលរកដំណោះស្រាយ។ នៅក្នុងករណីគ្មានការឆ្លើយតបពីអភិបាលខេត្តនៅក្នុងរយៈពេល ៣០ថ្ងៃ ផែនការ DP5 ត្រូវចាត់ទុកថាបានទទួលការអនុម័តគាំទ្រ។

ការរៀបចំកម្មវិធី IP3 ដែលធ្វើឡើងប្រចាំឆ្នាំ គឺជាដំណើរការដែលមានបីដំហាន៖

- ជំហានទី ១: ការកំណត់អត្តសញ្ញាណសំណើអាទិភាព ដែលពាក់ព័ន្ធជាមួយការពិនិត្យគម្រោងវិនិយោគដែលបានស្នើសុំ ការប៉ាន់ប្រមាណផលចំណេញ និងការចាត់ចែងពិគ្រោះយោបល់
- ជំហានទី ២: ការរៀបចំកម្មវិធី IP3 ដែលរួមទាំង ការវិភាគស្ថានភាព ការរៀបចំតារាងផែនការ ការចាត់ចែងសិក្ខាសាលាសមាហរណកម្ម ការចាត់ថ្នាក់គម្រោងទៅតាមស្ថានភាពនៃមូលនិធិ និងការរៀបចំអនុសាសន៍

សម្រាប់សុំការអនុម័តគាំទ្រពីក្រុមប្រឹក្សាស្រុក និងគណៈកម្មការសម្របសម្រួលថ្នាក់ស្រុក។ សិក្ខាសាលាសមាហរណកម្មគឺជាផ្នែកសំខាន់មួយនៃដំណើរការកសាងផែនការ ដែលមន្ទីរពាក់ព័ន្ធ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអញ្ជើញចូលរួមដើម្បីរួមចំណែកជាហិរញ្ញវត្ថុ និងបច្ចេកទេស។

- ជំហានទី ៣: ការនុម័តគាំទ្រលើកម្មវិធី IP3 ត្រូវការឲ្យមានយោបល់ពី និងការគាំទ្រជាមុនពីក្រុមប្រឹក្សាស្រុក និងការអនុម័តគាំទ្រដោយអភិបាលខេត្ត។

សំណើគម្រោងកម្មវិធី IP3 ត្រូវចាត់ជាក្រុម នៅក្នុងតារាងម៉ាទ្រិកផែនការៈ គម្រោងដែលស្ថិតក្រោមការអនុវត្តរួចមកហើយ គម្រោងដែលមានការប្តេជ្ញាផ្តល់មូលនិធិ និងគម្រោងដែលគ្មានការប្តេជ្ញាផ្តល់មូលនិធិ។

មន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត នៅតែអនុវត្តជារួមតាមគោលការណ៍ គោលនយោបាយ និងច្បាប់ និងបទប្បញ្ញត្តិនានារបស់ក្រសួងសាមីនៅថ្នាក់កណ្តាល ប៉ុន្តែការកសាងផែនការរបស់ពួកគេត្រូវឆ្លុះបញ្ចាំងអំពីតម្រូវការ និងការប្រឈមនានានៅមូលដ្ឋាន។ ផែនការប្រចាំឆ្នាំ និងផែនការរយៈពេលបីឆ្នាំ ត្រូវដាក់ជូនជាមួយសំណើថវិកាទៅក្រសួងនៅថ្នាក់កណ្តាល ដើម្បីពិនិត្យ និងអនុម័តគាំទ្រមុននឹងថវិកាគ្រោងនេះត្រូវដាក់ជូនជាបន្តទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីអនុម័ត។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចរចាជាមួយក្រសួងពាក់ព័ន្ធដើម្បីកែសម្រួលថវិកា ដោយផ្អែកលើកម្រិតថវិកាអតិបរមា ដែលបានកំណត់ជាមុនដោយរាជរដ្ឋាភិបាល មុននឹងថវិកាដែលបានអនុម័តត្រូវផ្ទេរទៅមន្ទីរនៅថ្នាក់មូលដ្ឋាន តាមរយៈក្រសួងសាមី។ ការអនុវត្តគម្រោងជាក់លាក់ពីសំណាក់មន្ទីរនៅថ្នាក់ក្រោមជាតិត្រូវផ្អែកលើលក្ខខណ្ឌថវិកាដែលកំណត់នៅក្នុងក្រសួងសាមីនៅថ្នាក់កណ្តាល។ ឧទាហរណ៍អំពីលក្ខខណ្ឌគោលសម្រាប់មន្ទីរធនធានទឹក និងឧតុនិយមខេត្ត ត្រូវបានកំណត់ត្រឹម ៥០០-១០០០ លានរៀល។ ការអនុវត្តគម្រោងដែលមានតម្លៃខ្ពស់ជាងលក្ខខណ្ឌគោលនេះ ត្រូវធ្វើឡើងដោយក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ។ ការកសាងផែនការ នីតិវិធីអនុម័ត និងការអនុវត្ត អាចកែប្រែនៅក្រោយមានការផ្ទេរមុខងាររបស់ក្រសួងពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ អនុលោមតាមច្បាប់សរីរាង្គ។ បច្ចុប្បន្ននេះ ឧបសគ្គចំបងៗសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ឲ្យមានប្រសិទ្ធភាពនៅតាមមន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត គឺថវិកា និងសមត្ថភាពដែលមានក្នុងកម្រិតកំណត់។

ការកសាងផែនការអភិវឌ្ឍន៍ឃុំ ត្រូវអនុវត្តតាមដំណើរការដែលមានប្រាំជំហានៈ

- ជំហានទី១: រៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ ដែលកំណត់អត្តសញ្ញាណតម្រូវការរបស់ឃុំ គោលបំណង និងយុទ្ធសាស្ត្រ និងការប៉ាន់ស្មានអំពីការចំណាយធនធាន (ដើមទុន និងចរន្ត) សម្រាប់រយៈពេលប្រាំឆ្នាំ
- ជំហានទី២: ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដែលរួមទាំង សហគមន៍មូលដ្ឋាន មន្ទីរពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សមាជិកក្រុមប្រឹក្សាឃុំ អ្នកសម្របសម្រួលថ្នាក់ខេត្ត និងស្រុក និងអ្នកឯកទេសកសាងផែនការ
- ជំហានទី៣: ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ (CDP)
- ជំហានទី ៤: ការអនុម័តគាំទ្រលើផែនការអភិវឌ្ឍន៍ឃុំ (CDP)
- ជំហានទី ៥: ការពិនិត្យតាមដាន និងវាយតម្លៃ។

គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ (CPBC) ត្រូវបានបង្កើត ដើម្បីរៀបចំ CDP5 និង CIP3។ ត្រូវដាក់ជូនសេចក្តីព្រាង CDP5 ទៅអភិបាលខេត្ត តាមរយៈអភិបាលស្រុក ដើម្បីអនុម័ត។ ការពិនិត្យផែនការនេះធ្វើ

ឡើងដោយមានសេវាជំនួយពីរដ្ឋបាលមូលដ្ឋាន មន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត និងមន្ទីរផែនការ (DOP) ។ គណៈកម្មាធិការ CPBC និងស្មៀនឃុំ នឹងកែសម្រួល CDP5 ទៅតាមអនុសាសន៍របស់អភិបាលខេត្ត ដែលបន្ទាប់ពីនោះ ក្រុមប្រឹក្សាឃុំនឹងអនុម័តលើផែនការនេះ។ ការរៀបចំ CIP3 ត្រូវធ្វើឡើងប្រចាំឆ្នាំ ទៅតាមជំហានដូចគ្នា ប៉ុន្តែការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា និងការបូកសរុបយោបល់ ត្រូវធ្វើឡើងនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក (DIW) ដែលរៀបចំឡើងនៅក្នុងខែ តុលា ឬវិច្ឆិកា។ ជំហានទី២ និង ទី៣ មានសារៈសំខាន់ណាស់សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការផ្តល់ជំនួយដទៃទៀត ដោយសារជំហានទាំងនេះផ្តល់ឱកាសសម្រាប់បញ្ចូលគម្រោងដែលជាការចង់បានរបស់ពួកគេទៅក្នុង CDP5 និង CIP3 និងមានការឯកភាពគ្នាជាបណ្តោះអាសន្នជាមួយក្រុមប្រឹក្សាឃុំនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក។

## ៣.៣ វិធាននៃដំណើរការប្រើប្រាស់សម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ

### ក្របខ័ណ្ឌសមាសភាគ CARP

ក្របខ័ណ្ឌសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុរួមមាន ក្រុមការងារមន្ត្រីបង្គោលថ្នាក់ជាតិ (NWG) និងក្រុមការងារបច្ចេកទេស (TWGs) ដែលបង្កើតឡើងនៅក្នុងខេត្តនីមួយៗ នៅក្រោមខុទ្ទកាល័យអភិបាលខេត្ត។ សមាជិក NWG តំណាងឲ្យមន្ទីរពាក់ព័ន្ធនានា (MAFF, EIA/MOE, CCD/MOE, GIS/MOE, NCDM, MOWRAM, MLMUPC, និង NCDD)។ តួនាទីរបស់ NWG គឺសម្របសម្រួលកិច្ចសហប្រតិបត្តិការ និងការប្រាស្រ័យទាក់ទងជាមួយក្រសួងសាមីរបស់ខ្លួនឲ្យចូលរួមក្នុងការអនុវត្តការងារប្រែប្រួលអាកាសធាតុ កសាងសមត្ថភាព និងការរួមបញ្ចូលការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការ និងគោលនយោបាយ និងផ្តល់យោបល់ដល់ TWGs។ TWGs មានអភិបាលរងខេត្តជាប្រធាន និងមានសមាជិកដែលតែងតាំងដោយមន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត ការិយាល័យស្រុក និងក្រុមប្រឹក្សាឃុំ។ TWGs ចូលរួមនៅក្នុងកិច្ចប្រជុំនានា ផ្តល់យោបល់លើគម្រោងអនុវត្តបង្ហាញ និងចូលរួមក្នុងវគ្គបណ្តុះបណ្តាលនានាអំពីការកសាងផែនការ និងការអនុវត្តកិច្ចការប្រែប្រួលអាកាសធាតុ។ មានការរំពឹងថា TWGs អាចមាននាទីជាអង្គភាពសម្របសម្រួលសកម្មភាពប្រែប្រួលអាកាសធាតុ និងការកសាងផែនការនៅថ្នាក់ខេត្ត ដោយទទួលសមត្ថភាពតាមរយៈការបណ្តុះបណ្តាលដែលចាត់ចែងឡើងដោយ CARP ស្របជាមួយគម្រោង LDCF។

### វិធានសម្រាប់កសាងផែនការ និងបញ្ចូលគម្រោងប្រែប្រួលអាកាសធាតុនៅក្នុងឃុំគោលដៅ

ដូចបានកត់សំគាល់ពីខាងដើម ធាតុចេញសំខាន់មួយរបស់ CARP គឺការអនុវត្តបង្ហាញគម្រោងបន្សាំទាំងប្រាំមួយនៅក្នុងតំបន់ឆ្នេរ ក្នុងឃុំចំនួនប្រាំបី នៃស្រុកព្រៃនប់ និងមណ្ឌលសីមា ក្នុងខេត្តព្រះសីហនុ និងខេត្តកោះកុង។ គម្រោងទាំងនោះគឺ៖

១. កម្មវិធីបណ្តុះបណ្តាលកសិកម្មចម្រុះសម្រាប់ (ក) បុគ្គលិកផ្សព្វផ្សាយកសិកម្ម/ជលផល និង (ខ) គ្រួសារនានា អំពីយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុពហុមាត្រដ្ឋាន និងកសិកម្មចម្រុះ (ការរួមបញ្ចូលដំណាំ ការចិញ្ចឹមសត្វ ត្រី ទឹក) នៅសហគមន៍គោលដៅ។ សកម្មភាពទាំងនេះ អាច

អនុវត្តបន្តពីការវិភាគប្រព័ន្ធកេ្សត្របរិស្ថានដែលជាផ្នែករួមមួយ និងរួមបញ្ចូលការអនុវត្តបង្ហាញអំពីវិធានការគ្រប់គ្រងនៅតាមកសិដ្ឋាន។ សកម្មភាពអនុវត្តបង្ហាញត្រូវបានស្នើឡើងសម្រាប់ការអនុវត្តក្រោមភាពជាដៃគូ ជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២. គម្រោងសហគមន៍នេសាទនៅពាមក្រសោប ជាពិសេស ដើម្បីពង្រឹងវិធានការច្បាប់ និងពង្រឹងការអនុវត្ត ដែលជាលក្ខខណ្ឌដំបូងសម្រាប់ធ្វើឲ្យបចិញ្ចឹមជីវិតរបស់សហគមន៍នេសាទ កាន់តែបន្សាំបានទៅនឹងការប្រែប្រួលអាកាសធាតុ។ សកម្មភាពអនុវត្តបង្ហាញនេះត្រូវបានស្នើឡើងសម្រាប់ការអនុវត្តក្រោមភាពជាដៃគូជាមួយរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣. ការលើកកំពស់ និងបង្កើនវត្តមានពូជដំណាំដែលឆាប់ផ្តល់ផល ជាពិសេស ស្រូវស្រាលរដូវវស្សា អាចសម្រួលដល់ការប្រមូលផលមុនពេលទឹកជំនន់ធំមកដល់ និងការឡើងកំពស់ទឹកសមុទ្រនៅក្នុងឃុំគោលដៅ។ គេត្រូវសាកល្បងពូជដំណាំបែបនេះ (ដោយកសិករមិនមែនជាអ្នកបង់ខាត) នៅក្នុងទីតាំងដាក់លាក់ទំនងជាមានប្រសិទ្ធភាព។ សកម្មភាពអនុវត្តបង្ហាញនេះត្រូវបានស្នើឡើងសម្រាប់ការអនុវត្តក្រោមភាពជាដៃគូជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤. លើកកំពស់ការចិញ្ចឹមសត្វនៅក្នុងឃុំចំនួន ៥ ដោយប្រើប្រាស់ប្រព័ន្ធទុនបង្វិលសម្រាប់កែលម្អពូជជាបន្តបន្ទាប់ ជាការឆ្លើយតបទៅនឹងបញ្ហាទឹកជំនន់។ សកម្មភាពអនុវត្តបង្ហាញនេះត្រូវបានស្នើឡើងសម្រាប់ការអនុវត្តក្រោមភាពជាដៃគូជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សត្វចិញ្ចឹម និងកសិកម្ម (CelAgrid) ដោយសហការជាមួយអង្គភាពគ្រប់គ្រងគម្រោង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤. ការបង្កើនការយល់ដឹង និងការបណ្តុះបណ្តាលអំពីការប្រែប្រួលអាកាសធាតុស្តីពីការប្រព័ន្ធស្រោចស្រពដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅក្នុងឃុំគោលដៅនឹងត្រូវអនុវត្តដោយប្រើប្រាស់បទពិសោធន៍ពីការងារកន្លងមកនៅកម្ពុជា។ ការងារបណ្តុះបណ្តាលនឹងត្រូវអនុវត្ត តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល នាយកដ្ឋានអប់រំបរិស្ថាននៃក្រសួងបរិស្ថាន និងក្រុមការងារបច្ចេកទេសដែលមានភារៈទទួលខុសត្រូវលើការអនុវត្ត និងការបង្កើតការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ។

៥. វិធានការបន្សាំត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំនៅក្នុងឃុំគោលដៅ។ សកម្មភាពបង្ហាញជាក់លាក់នឹងត្រូវអនុវត្ត ដោយផ្អែកលើសកម្មភាពគ្រោងទុកនៅក្នុងផែនការវិនិយោគឃុំឆ្នាំ ២០១៣ ដែលនឹងធ្វើឲ្យឃុំកាន់តែមានភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ សកម្មភាពអនុវត្តបង្ហាញនឹងធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ ស្រុក និងក្រុមការងារបច្ចេកទេស។

ការកំណត់អត្តសញ្ញាណ ការជ្រើសរើស និងការរួមបញ្ចូលគម្រោងអនុវត្តបង្ហាញ បានធ្វើឡើងតាមជំហាននានា ដែលមានចែងខាងក្រោម ទន្ទឹមនឹងការប្រើប្រាស់ប្រាស់រចនាសម្ព័ន្ធដែលបានបង្កើតនៅថ្នាក់ខេត្តនិងឃុំ ដូចមានអធិប្បាយខាងក្រោម៖

- ការវិភាគស្ថានភាព៖ កិច្ចការនេះបានធ្វើឡើង ដោយផ្អែកលើការពិនិត្យលើការសិក្សានានានៅក្រោម CARP និងការពិគ្រោះយោបល់នៅតាមមូលដ្ឋានជាមួយអ្នកពាក់ព័ន្ធនានា ដែលរាប់ចាប់ពី TWGs, ក្រុមប្រឹក្សាឃុំ និងអ្នកភូមិ ដែលជាមូលដ្ឋានសម្រាប់ការកំណត់អត្តសញ្ញាណហានិភ័យអាកាសធាតុ និងការឆ្លើយតប។ ការសិក្សានៅក្រោម CARP រួមមាន៖ ការវាយតម្លៃយុទ្ធសាស្ត្រទប់ទល់ ការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យរបស់សហគមន៍ពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរ ការវិភាគថ្លៃចំណាយ និងផលចំណេញសម្រាប់ការកែប្រែទម្លាប់ក្នុងកសិកម្មនៅក្នុងតំបន់ឆ្នេរ និងការគាំទ្រដល់ការអប់រំអំពីការប្រែប្រួលអាកាសធាតុ បង្កើតការយល់ដឹង និងការពង្រឹងគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹក។
- ការកំណត់អត្តសញ្ញាណគម្រោងបង្ហាញ៖ គម្រោងប្រមាណ២០ ត្រូវបានកំណត់តាមរយៈការពិគ្រោះយោបល់ និងការចាត់អាទិភាពដែលបានធ្វើឡើងនៅក្នុងខែកក្កដា-វិច្ឆិកា ឆ្នាំ២០១២ ជាមួយដៃគូសហការ អង្គការមិនមែនរដ្ឋាភិបាល ក្រុមការងារបច្ចេកទេស ក្រុមប្រឹក្សាឃុំ និងអ្នកភូមិ។ ចំនួនគម្រោងត្រូវបានកាត់បន្ថយជាបន្តមកត្រឹម ៦ ដូចមានបង្ហាញខាងលើ ដោយផ្អែកលើការចាត់ជាលំដាប់ និងដំណើរការជ្រើសរើស ដែលមានការពាក់ព័ន្ធនៃក្រុមការងារបច្ចេកទេស និងក្រុមប្រឹក្សាឃុំ។
- ការរួមបញ្ចូលគម្រោងបង្ហាញនៅក្នុង CIP3: គម្រោងទាំងនេះត្រូវបានរៀបចំឡើងទៅតាមទម្រង់ដែលមានស្រាប់របស់ឃុំ និងសម្រាប់ក្រុមប្រឹក្សាឃុំពិចារណា និងរួមបញ្ចូលនៅក្នុង CIP3, ដែលនឹងត្រូវពិនិត្យនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ដែលបានធ្វើឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ ។ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពប្រែប្រួលអាកាសធាតុមិនអាចរួមបញ្ចូលនៅក្នុង CDP5 បច្ចុប្បន្នបានឡើយ ដោយសារផែនការនេះរៀបចំឡើងសម្រាប់តែរយៈពេលប្រាំឆ្នាំ។ គំរូមួយសម្រាប់ការជ្រើសរើសគម្រោងដោយផ្អែកលើការប្រែប្រួលអាកាសធាតុ នៃគម្រោងវិនិយោគឃុំ ក៏បានរៀបចំឡើងផងដែរ។
- ការអនុវត្ត៖ គម្រោងនានាឥឡូវនេះស្ថិតក្នុងការអនុវត្តសម្រាប់រយៈពេលពីរឆ្នាំ (២០១៣-២០១៤) ក្រោមកិច្ចសហការជាមួយដៃគូនៅថ្នាក់ខេត្ត និងឃុំ ដែលបានកត់សំគាល់ពីខាងដើម។

មេរៀនទទួលបានពីវិធាននៃការអនុវត្តនេះមានដូចតទៅ៖

- នីតិវិធី និងគោលការណ៍ណែនាំសម្រាប់កសាងផែនការអនុវត្តដែលបច្ចុប្បន្ននេះមាននៅថ្នាក់ក្រោមជាតិ ផ្តល់ឱកាសយ៉ាងល្អសម្រាប់សមាហរណកម្មការប្រែប្រួលអាកាសធាតុ។
- កង្វះសមត្ថភាពនិងមូលនិធិនៅថ្នាក់ក្រោមជាតិ គឺជាឧបសគ្គចំបងសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុឲ្យបានសមស្រប។ ថវិកាឃុំបច្ចុប្បន្ននេះមានប្រមាណ ២០.០០០ដុល្លាអាមេរិក ដែលអាចផ្តល់ឲ្យតែសម្រាប់ស្តារហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដូចជាផ្លូវថ្នល់ អណ្តូងទឹក និងការត្រងទឹកភ្លៀងប៉ុណ្ណោះ។
- បច្ចុប្បន្ននេះ គ្មានយន្តការសម្របសម្រួលច្បាស់លាស់ដែលមានប្រសិទ្ធភាពសម្រាប់អនុវត្តនៅថ្នាក់ជាតិឡើយ ប៉ុន្តែក្រុមការងារបច្ចេកទេសដែលបានបង្កើតឡើងអាចអនុវត្តកិច្ចការនេះ ក្នុងករណីដែលមានការកសាង

សមត្ថភាពរបស់ពួកគេជាបន្តបន្ទាប់ តាមរយៈសកម្មភាពបណ្តុះបណ្តាលដែលបានធ្វើឡើងនៅក្រោម CARP និង LDCF។

- មានការគាំទ្រ និងការប្រាស្រ័យទាក់ទងគ្នាក្នុងកម្រិតកំណត់ រវាងមន្ទីរពាក់ព័ន្ធ និងក្រុមប្រឹក្សាឃុំ នៅក្នុងពេលរៀបចំ CDP5 និង CIP3 ដោយសារតែមានថវិកាមិនគ្រប់គ្រាន់ និងសមត្ថភាពទាបនៅក្នុងមន្ទីរពាក់ព័ន្ធ។ ក្រុមការងារបច្ចេកទេស អាចមានជំហរសមស្របក្នុងការផ្តល់ការគាំទ្របច្ចេកទេសទៅអនាគត។
- ការរួមបញ្ចូលគម្រោង ស្តីពីការប្រែប្រួលអាកាសធាតុនៅក្នុងកម្រងទិន្នន័យឃុំបច្ចុប្បន្ននេះ បង្ហាញពីបញ្ហាព្រោះតែឈ្មោះគម្រោងត្រូវបានបដិសេធ ដោយសារមិនស្របគ្នាជាមួយលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយក្រសួងផែនការ និងមន្ទីរផែនការ។
- ទោះបីទម្រង់បច្ចុប្បន្ននៃសំណើសម្រាប់ថ្នាក់ឃុំមានផ្នែកស្តីពីបរិស្ថានក៏ដោយ ទម្រង់នេះគ្មានចែងអំពីបញ្ហាដែលទាក់ទងជាក់លាក់នឹងការប្រែប្រួលអាកាសធាតុឡើយ។ ដូច្នេះ CARP បានស្នើឲ្យបង្កើតគំរូអំពីការប្រែប្រួលអាកាសធាតុ ដែលអាចរួមបញ្ចូលជាផ្លូវការនៅក្នុងគោលការណ៍ណែនាំរបស់រដ្ឋាភិបាលទៅអនាគត។

## IV. សំណើយន្តការសម្របសម្រួលសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ

ដើម្បីរួមបញ្ចូលការប្រែប្រួលអាកាសធាតុឲ្យមានប្រសិទ្ធភាព និងមាននិរន្តរភាព គេត្រូវគិតគូរ និងកែលម្អផ្នែកចំបងៗចំនួនបួន ដែលរួមមានការសម្របសម្រួលស្ថាប័ន ការកសាងផែនការ និងនីតិវិធីលើកថវិកា ការអភិវឌ្ឍសមត្ថភាព និងការពិនិត្យតាមដាន និងវាយតម្លៃ។

*ការសម្របសម្រួលស្ថាប័ន៖* ដូចដែលបានពិភាក្សាខាងលើ តួនាទីចំបងរបស់ NCCC នៅមានកម្រិតត្រឹមប្រតិបត្តិការនៅថ្នាក់ជាតិ។ គណៈកម្មាធិការនេះមានធនធានតិចតួច និងសមត្ថភាពតិចតួចដើម្បីមានឥទ្ធិពលលើការកសាងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ។ ជាការចាំបាច់គឺត្រូវពិចារណាផ្តល់ TWGs ដែលមានអាណត្តិច្បាស់លាស់សម្រាប់សម្របសម្រួល និងកសាងផែនការប្រែប្រួលអាកាសធាតុ ដោយសារក្រុមការងារនេះមានសមត្ថភាពគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចការនេះបាន។ ការកសាងផែនការ និងរចនាសម្ព័ន្ធស្ថាប័ននៅថ្នាក់ក្រោមជាតិបានបង្ហាញឲ្យឃើញកាន់តែច្បាស់ និងមានភាពរឹងមាំ ដែលអាចរួមបញ្ចូលស្ទើរតែគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍ ដែលរួមទាំងការប្រែប្រួលអាកាសធាតុផងដែរ នៅក្នុង DP និង IP3 នៅថ្នាក់ក្រោមជាតិ។ ជាផ្នែកមួយនៃកំណែទម្រង់ D&D មុខងារ និងធនធានរបស់ក្រសួងនៅថ្នាក់ជាតិ នឹងត្រូវផ្ទេរទៅរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ទោះបីអាចទាមទារពេលយ៉ាងវែងក៏ដោយ មុននឹងអាចធ្វើទៅបាន។ ដូច្នេះ ជាការសមហេតុផលដែលត្រូវពង្រឹងទម្លាប់ល្អពីការអនុវត្ត CARP, ដោយសារគម្រោងនេះមានពេល និងធនធានគ្រប់គ្រាន់ដើម្បីកសាងសមត្ថភាពដែលផ្តោតចំគោលដៅ និងជាបន្តបន្ទាប់។ គម្រោងដទៃទៀត ដូចជា PPCR និង គម្រោងរដ្ឋាភិបាលមូលដ្ឋាន និងប្រែប្រួលអាកាសធាតុ(LGCC) ក៏មានការប៉ុនប៉ងបង្កើតគំរូនានាសម្រាប់បញ្ជ្រាបការប្រែប្រួអាកាសធាតុនៅថ្នាក់ក្រោមជាតិផងដែរ ប៉ុន្តែដោយគ្មានការអនុវត្តជាក់ស្តែងនៅក្នុងសហគមន៍ឡើយ ឬមានថវិកាក្នុងកម្រិតកំណត់។

ដោយពង្រឹងបន្ថែមលើ NCCC និងបទពិសោធន៍របស់ TWG មានការស្នើឲ្យបង្កើត*អង្គភាពសម្របសម្រួលការប្រែប្រួលអាកាសធាតុ(CCCU)* ឬអាចជាគណៈកម្មាធិការប្រែប្រួលអាកាសធាតុ *(CCCC)* ដែលមានលេខាធិការដ្ឋានដែលស្ថិតនៅក្នុងខុទ្ទកាល័យអភិបាលខេត្ត។ ក្រុមការងារបច្ចេកទេសបច្ចុប្បន្ន អាចបម្លែងទៅជា CCCU ដោយមានសមាជិកបន្ថែមមកពីវិស័យដទៃទៀត ដែលរួមទាំង ដូចជា សុខាភិបាល អភិវឌ្ឍន៍ជនបទ ផលផល ថាមពល ការដឹកជញ្ជូន អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍(CBO) គណៈកម្មការសហគមន៍ប្រើប្រាស់ទឹក(FWUC) និងវិស័យឯកជន។ នៅក្នុងពេលនេះ TWGs អាចចាត់អញ្ជើញតំណាងមកពីមន្ទីរពាក់ព័ន្ធ ឬស្ថាប័ននានា ដើម្បីចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលដែលផ្តោតចំគោលដៅ។ ប្រធាន CCCU គួរត្រូវបានជ្រើសរើសពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាខេត្ត ដែលមានស្ថានភាពរឹងមាំ ក្នុងការលើកឡើងអំពីការប្រែប្រួលអាកាសធាតុនៅក្នុងកិច្ចប្រជុំជាទៀងទាត់របស់ក្រុមប្រឹក្សានេះ។ តួនាទីរបស់ CCCU គឺការផ្តល់ជំនួយបច្ចេកទេសអំពីការបន្ស៊ាំនឹងការប្រែប្រួលបច្ចេកទេស ពិនិត្យ និងអនុម័តគាំទ្រគម្រោង និងផែនការប្រែប្រួលអាកាសធាតុ លើកកំពស់ការកសាងសមត្ថភាពសម្របសម្រួលលំហូរមូលនិធិ និងធ្វើការពិនិត្យតាមដាន និងវាយតម្លៃ។ ការគាំទ្របច្ចេកទេសពី NCCC អាចធ្វើបានដែលអាចតាមរយៈ CCTT – ដើម្បីណែនាំអំពីការកសាងយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាព។ លេខាធិការដ្ឋានបច្ចេកទេសតូចមួយអាចបង្កើតឡើងនៅក្នុងខុទ្ទកាល័យអភិបាលខេត្តដោយមានបុគ្គលិកមកពីមន្ទីរពាក់ព័ន្ធ ពោលគឺមន្ទីរបរិស្ថាន កសិកម្ម ព្រៃឈើ គ្រប់គ្រងគ្រោះមហន្តរាយ ការគ្រប់គ្រងដី និងមានសម្បទាសម្រាប់ GIS/កសាងផែនការ។ ការផ្តល់មូលនិធិដល់ CCCU និងលេខាធិការដ្ឋានរបស់អង្គភាពនេះ គួរតែជាផ្នែកមួយនៃថវិកាខេត្ត ដែលបញ្ជូនតាមរយៈ NCDD។

***ការកសាងផែនការ និងនីតិវិធីលើកថវិកា* (PBP)**: នីតិវិធី និងគោលការណ៍ណែនាំសម្រាប់កសាងផែនការបច្ចុប្បន្ន ត្រូវបានរៀបចំយ៉ាងល្អ ប៉ុន្តែមានភាពខ្វះខាតដែលទាក់ទងនឹងទម្រង់សម្រាប់ការរួមបញ្ចូលសំណើប្រែប្រួលអាកាសធាតុ ដោយសារពុំមានរួមបញ្ចូលព័ត៌មានគ្រប់គ្រាន់ ការគិតគូរអំពីការបន្ស៊ាំ និងការគ្រប់គ្រងគ្រោះមហន្តរាយនៅមានកម្រិតកំណត់បំផុត ការចូលរួមរបស់មន្ទីរពាក់ព័ន្ធនៅក្នុងដំណើរការកសាងផែនការមិនទៀងទាត់ និងការយល់ដឹងជាទូទៅអំពីការពាក់ព័ន្ធនៃការប្រែប្រួលអាកាសធាតុសម្រាប់វិស័យនានា និងបរបិញ្ចឹមជីវិតនៅមានភាពទន់ខ្សោយ។ CARP បានព្យាយាមជំនះភាពខ្វះខាតទាំងនេះ តាមរយៈការកសាងសមត្ថភាព និងបន្តកិច្ចប្រឹងប្រែងរបស់ខ្លួនលើកិច្ចការនេះ។ ទោះជាយ៉ាងណាក៏ដោយ គួរមានការកែតម្រូវនៅក្នុងគោលការណ៍ណែនាំដែលមានស្រាប់តាមរយៈការពិនិត្យឡើងវិញ។ ឧបសគ្គសំខាន់មួយទៀតគឺកម្រិតទាបជាទូទៅនៃការផ្តល់មូលនិធិសម្រាប់ការកសាងផែនការនៅថ្នាក់ក្រោមជាតិនិងដោយឡែក ការប្រែប្រួលអាកាសធាតុ។ CCCU អាចតស៊ូមតិដើម្បីឲ្យមានការផ្តល់មូលនិធិកាន់តែច្រើនឡើងសម្រាប់ការប្រែប្រួលអាកាសធាតុ ដែលជាផ្នែកមួយនៃការផ្ទេរដែលបានគ្រោងទុកនូវធនធានពីរដ្ឋាភិបាលថ្នាក់កណ្តាលទៅថ្នាក់ក្រោមជាតិ។ ប៉ុន្តែប្រការសំខាន់ជាងនេះគឺសំណួរអំពីការបន្សុីគ្នានៃទិដ្ឋភាពនេះនៅក្នុងកំណែទម្រង់ D&D ជាមួយកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដែលអនុវត្តដោយ MEF។ ជាការច្បាស់ណាស់ថា បើគ្មានការផ្តល់មូលនិធិគ្រប់គ្រាន់ទេនោះ ការធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុ អាចលំបាកសម្រេចឲ្យបាន។ សព្វថ្ងៃនេះ មានត្រឹមតែ ២០% នៃថវិកាសរុបសម្រាប់ការប្រែប្រួលអាកាសធាតុត្រូវបានផ្តល់តាមរយៈការផ្ទេរទៅថ្នាក់ក្រោមជាតិ ហើយបុរេសនាសម្រាប់បង្កើនការផ្តល់មូលនិធិនៅក្នុងអនាគតខ្លីខាងមុខនេះគ្មានភាពច្បាស់លាស់ឡើយ។ NCDD និង NCCC ត្រូវធ្វើការជាមួយគ្នាក្នុងការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទាន

ប្រែប្រួលអាកាសធាតុ ដែលអាចធានាឲ្យមានការផ្តល់មូលនិធិគ្រប់គ្រាន់ពីរាជរដ្ឋាភិបាលកម្ពុជា និងយន្តការមូលនិធិអន្តរជាតិ ដូចជា CIF, មូលនិធិអាកាសធាតុបៃតង (GCF), មូលនិធិបរិស្ថានពិភពលោក (GEF) និងមូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច (LDCF), និងមូលនិធិបន្សាំ។ល។

*ការកសាងសមត្ថភាព៖* មានការអះអាងនៅក្នុងការសិក្សា និងរបាយការណ៍ជាច្រើនថា សមត្ថភាពស្ថាប័ន និងចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុនៅទន់ខ្សោយគ្រប់លំដាប់ថ្នាក់ ហើយថ្នាក់ក្រោមជាតិមានភាពទន់ខ្សោយជាងគេ។ ការអភិវឌ្ឍសមត្ថភាពជាបន្តសម្រាប់ CCCU និងលេខាធិការដ្ឋាននៃអង្គភាពនេះ គឺជាតម្រូវការចាំបាច់ដើម្បីអាចឲ្យមានការសម្របសម្រួលការកសាងផែនការ និងលើកកំពស់ការបង្កើតការយល់ដឹងប្រកបដោយប្រសិទ្ធភាព។ NCCC និង CCCA អាចជួយនៅក្នុងការពង្រីកការអភិវឌ្ឍសមត្ថភាពដែលកំពុងអនុវត្តនៅក្នុងឃុំគោលដៅនៃ CARP និងការពង្រីកការងារនេះថែមទៀតនៅក្នុងតំបន់ឆ្នេរ និងបណ្តាខេត្តផ្សេងទៀត ដោយពង្រឹងបន្ថែមលើបទពិសោធន៍ និងមេរៀនដែលទទួលបានពីពេលកន្លងមក។ សកម្មភាពបច្ចុប្បន្នក្នុងតំបន់ឆ្នេរគួរតែបានពង្រីកនិងចម្លងសម្រាប់ខេត្តដទៃទៀតជាវិធានដែលមាននិរន្តរភាពសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍស្ថាប័ននៅថ្នាក់ក្រោមជាតិ សម្រាប់ខេត្តមួយចំនួន ជាវិធានដែលមាននិរន្តរភាពសម្រាប់អន្តរាគមន៍។

*ការពិនិត្យតាមដាន និងវាយតម្លៃ៖* ប្រព័ន្ធ M&E ដែលមានស្រាប់សម្រាប់ DP5 ចែងពិស្តារអំពីទិដ្ឋភាពនានានៃការអភិវឌ្ឍ និងរដ្ឋបាល ប៉ុន្តែមានសូចនាករតិចតួចបំផុតសម្រាប់ការប្រែប្រួលអាកាសធាតុ។ សូចនាករខ្លះអាចមានការពាក់ព័ន្ធសម្រាប់សេដ្ឋកិច្ច និងសម្រាប់ការប្រែប្រួលអាកាសធាតុផងដែរ ដូចជា ប្រវែងទំនប់ទឹកប្រៃដែលបានសង់ ផ្ទៃដីដែលបានដាំកោងកាង និងការសាកល្បងពូជស្រូវស្រាល។ កម្រងទិន្នន័យបច្ចុប្បន្ននេះអំពីភូមិ ឃុំ និងស្រុក ពុំមានព័ត៌មានគ្រប់គ្រាន់អំពីកត្តាប្រែប្រួលអាកាសធាតុឡើយ។ ព័ត៌មាននេះច្រើនតែពាក់ព័ន្ធនឹងផលប៉ះពាល់ពីគ្រោះមហន្តរាយធម្មជាតិ។ លើសពីនេះ ពុំមានសង្គតិភាពរវាងកម្រងទិន្នន័យទាំងនេះឡើយ ដូចជា កម្រងទិន្នន័យឃុំមានព័ត៌មានអំពីទំហំដីដែលរងគ្រោះដោយារទឹកជំនន់ និងគ្រោះរាំងស្ងួត ចំណែកទិន្នន័យភូមិមានកំណត់ត្រាអំពីចំនួនប្រជាជនដែលរងគ្រោះដោយសារទឹកជំនន់។ ដូច្នេះ ព័ត៌មានភូមិ អាចមិនមានសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃនៅកម្រិតឃុំ។ ដូច្នេះ ផ្អែកលើទិន្នន័យ និងព័ត៌មានដែលប្រមូលបានសមស្របនៅកម្រិតភូមិ និងឃុំ គេគួរបង្កើតសូចនាករបន្ថែមទៀត និងបន្ទាប់មកបួមបញ្ចូលទៅក្នុងកម្រងទិន្នន័យខេត្តនៅក្រោមការណែនាំរបស់ CCCU។

## V. ទំនាក់ទំនងរវាងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

CARP ត្រូវបានរៀបចំឡើងតាមរបៀបវារៈបន្សាំនឹងអាកាសធាតុនៅក្នុងតំបន់ឆ្នេរ ដោយមានកង្វល់ និងឱកាសដោយឡែក ដែលកង្វល់ និងឱកាសមួយចំនួន មានលក្ខណៈដូចគ្នាសម្រាប់ផ្នែកនានានៃអាងទន្លេមេគង្គនៅក្នុងប្រទេសនេះ ចំណែកកង្វល់ និងឱកាសដទៃទៀត មានភាពជាក់លាក់សម្រាប់តែតំបន់ឆ្នេរប៉ុណ្ណោះ។

មេរៀននានាកំពុងតែបានសិក្សា (នៅក្នុង និងក្រៅ CARP និងគម្រោង LDCF) អំពីសក្តានុពល និងភាពជាក់ស្តែងនៃការបន្សាំនឹងអាកាសធាតុនៅថ្នាក់ក្រោមជាតិ។ មេរៀនបន្ថែមទៀត និងការចងក្រងជាឯកសារ នឹងធ្វើបានល្អនៅក្រោយការបញ្ចប់គម្រោងនេះ ដូចជា អំពីអត្ថប្រយោជន៍ពេញលេញនៃបច្ចេកវិទ្យាកែលម្អផលិតកម្ម

និងអំពីប្រព័ន្ធអេកូឡូស៊ីដែលមានដំណើរការពេញលេញ ដែលទាំងពីរនេះពិតជារួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជារួមសម្រាប់ជាតិ។
អន្តរកម្មជាមួយថ្នាក់ជាតិមាននៅក្នុងវិស័យនានាដូចតទៅៈ

- ការអប់រំ ការបង្កើតការយល់ដឹង និងការចូលរួមសកម្មរបស់សហគមន៍ៈ CARP ប្រតិបត្តិការនៅកម្រិតគ្រួសារ/សហគមន៍ និងនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ (ខេត្ត ស្រុក និងឃុំ) ដោយសង្កត់ធ្ងន់លើចំណងទាក់ទងរវាងរបបចិញ្ចឹមជីវិតដែលមាននិរន្តរភាពនិងដែលពឹងផ្អែកលើធនធាន ការកាត់បន្ថយភាពក្រីក្រ ការអភិរក្សបរិស្ថាន និងភាពធន់នឹងអាកាសធាតុ។ អត្ថប្រយោជន៍នៃការចូលរួមយ៉ាងសកម្មរបស់សហគមន៍ ត្រូវបានអះអាងយ៉ាងច្បាស់រួចមកហើយ នៅក្នុងដំណាក់កាលនេះនៃការអនុវត្ត CARP។ គួរកត់សំគាល់ថា CARP អាចរួមចំណែក*"បង្ហាញកស្តុតាងនៅមូលដ្ឋាន"*នៃវិធានបន្សាំ ដែលបានសាកល្បងនៅក្នុងអំឡុងពេលសាកល្បងសកម្មភាពនានានៅកម្រិតគ្រួសារ សហគមន៍ និងឃុំ។
- ការកសាងសមត្ថភាពស្ថាប័នៈ CARP ផ្តោតលើកង្វល់ដែលទាក់ទងនឹងអាកាសធាតុ ឱកាស ទំនាក់ទំនងរវាងហេតុនិងផល (ផលប៉ះពាល់សង្គម សេដ្ឋកិច្ច និងបរិស្ថាន) និង ជម្រើសគ្រប់គ្រងដែលអាចអនុវត្ត បាននៅថ្នាក់ក្រោមជាតិ។ ផ្នែកនានានៃកិច្ចប្រឹងប្រែងអប់រំ និងបង្កើតការយល់ដឹង មានលក្ខណៈជាក់លាក់សម្រាប់តំបន់ឆ្នេរ ដូចជា ការថែរក្សាទីជម្រក និងប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ និងសមុទ្រ និងផលប៉ះពាល់នៃកំណើនកំពស់ទឹកសមុទ្រ។ ផ្នែកដទៃទៀត ត្រូវបានអ្នកចូលរួមចាត់ទុកថាសំខាន់ផងដែរ គឺជាបញ្ហាទូទៅដែលទាក់ទងនឹងការណែនាំអំពីគោលគំនិតសំខាន់ៗ និងឧបករណ៍សម្រាប់ភាពធន់ និងការបន្សុំនឹងអាកាសធាតុ។

ការផ្សព្វផ្សាយកំពុងអនុវត្តតាមរយៈសេចក្តីរាយការណ៍តាមប្រធានបទ ការរៀបចំសម្ភារៈបណ្តុះបណ្តាល និងគោលការណ៍ណែនាំ (បច្ចុប្បន្ននេះ មានឯកសារបណ្តុះបណ្តាលចំនួន ២០) និងការចូលរួមយ៉ាងសកម្មនៅក្នុងសិក្ខាសាលា និងបណ្តាញនានា។

CARP មានការប្តេជ្ញាដើម្បីបន្តការពិភាក្សា ចែករំលែកការកត់សំគាល់ លើកស្នើ និងផ្តល់អនុសាសន៍ ដែលគាំទ្រដល់ដំណើរការបញ្ជ្រាបនៅថ្នាក់ជាតិដែលមានការវិវត្ត។ NCDD និង MOP មានភាពមោះមុត ក្នុងការចូលរួមជាដៃគូសំខាន់មួយនៅក្នុងកិច្ចការនេះ ជាមួយ NCCC និងលេខាធិការដ្ឋាន ដែលផ្តល់ការគាំទ្រសំខាន់ៗ"តាមវិធីជាច្រើន ដែលរួមទាំង ការធ្វើឲ្យមានភាពបំពេញគ្នាផងដែរ។ កិច្ចប្រឹងប្រែងនានាអាចរួមបញ្ចូលយ៉ាងងាយស្រួលនូវការពិគ្រោះយោបល់នៅកម្រិតទ្វេភាគី ជាមួយអង្គភាពនានា ដែលពាក់ព័ន្ធនៅក្នុងការបន្សាំនឹងអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅពេលដែលបទពិសោធន៍ដំបូង ត្រូវបានចងក្រងជាឯកសារ និងបង្កើតជាគោលគំនិតច្បាស់លាស់។

## VI. សេចក្តីសន្និដ្ឋាន

ការកសាងផែនការ និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុបច្ចុប្បន្ននេះកំពុងអនុវត្តនៅលំដាប់ថ្នាក់ខុសៗគ្នា ដោយមានវឌ្ឍភាពសម្រេចបានគួរឲ្យកត់សំគាល់នៅថ្នាក់ជាតិ។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យត្រូវបានអនុម័ត ដែលផ្តល់ក្របខ័ណ្ឌគោលនយោបាយពិស្តារសម្រាប់សមាហរណកម្មការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ កិច្ចផ្តួចផ្តើមមួយចំនួន

និងគម្រោងដែលមានស្រាប់នានា ត្រូវបានអនុវត្តនៅថ្នាក់ខេត្ត ដោយប្រើប្រាស់ទាំងវិធានរបស់រដ្ឋាភិបាល និងអន្តរជាតិសម្រាប់ការកសាងផែនការ។ សមាសភាគកសាងផែនការបន្សាំ និងភាពធន់នឹងអាកាសធាតុនៃ CCCA ត្រូវបានអនុវត្តតាំងពីឆ្នាំ ២០១២ នៅក្នុងឃុំចំនួនប្រាំបី នៅស្រុកព្រៃនប់ និងមណ្ឌលសីមា ក្នុងខេត្តព្រះសីហនុ និងកោះកុង។ វិធានរបស់ CARP – ការអនុវត្តសកម្មភាពបង្ហាញ និងសមាហរណកម្មការគិតគូរអំពីការប្រែប្រួលអាកាសធាតុនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ - បានផ្អែកលើនីតិវិធី និងគោលការណ៍ណែនាំ ដែលមានស្រាប់របស់រដ្ឋាភិបាលសម្រាប់កសាងផែនការសម្រាប់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ បទពិសោធន៍របស់ CARP បង្ហាញអំពីវត្តមានពិតប្រាកដនូវឱកាសសម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុង DP5 និង IP3។ ទោះជាយ៉ាងណាក៏ដោយកង្វះរចនាសម្ព័ន្ធស្ថាប័នផ្លូវការ និងគោលការណ៍ណែនាំ នឹងធ្វើឲ្យមានការលំបាកក្នុងការរក្សាដំណើរការបែបនេះនៅថ្នាក់ក្រោមជាតិ។ ផ្អែកលើការវិភាគពិស្តារអំពីរចនាសម្ព័ន្ធស្ថាប័នដែលមានស្រាប់សម្រាប់ការកសាងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងដោយគិតគូរផងដែរអំពីប៉ារ៉ាម៉ែត្រនៃកំណែទម្រង់ D&D ដែលកំពុងប្រព្រឹត្តទៅការបង្កើតអង្គភាពសម្របសម្រួលការប្រែប្រួលអាកាសធាតុ ជាផ្នែកមួយនៃ NCCC និង NCDD ត្រូវបានលើកស្នើឡើង។ អង្គភាពនេះនឹងអាចទទួលផលពីសមត្ថភាពដែលបានអភិវឌ្ឍន៍កន្លងមក នៅក្នុង TWGs ហើយ អាចទទួលសមាជិកបន្ថែមទៀតដោយប្រើប្រាស់គោលការណ៍និងបទប្បញ្ញត្តិរបស់ D&D។ កិច្ចការជាអាទិភាពគឺ កែលម្អនីតិវិធីកសាងផែនការ និងការលើកថវិកា លើកកំពស់ការអភិវឌ្ឍសមត្ថភាព និងបង្កើតប្រព័ន្ធ M&E សម្រាប់ ការកសាងផែនការនិងការអនុវត្តការងារប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ។ នៅពេលដែលក្របខ័ណ្ឌស្ថាប័នបានកែលម្អហើយ សម្រាប់ការកសាងផែនការប្រែប្រួលអកាសធាតុនិងការអនុវត្តត្រូវបានដាក់ឲ្យអនុវត្ត សកម្មភាពកំពុងតែអនុវត្តគួរតែបានពង្រីកទៅក្នុងកន្លែងដទៃទៀតក្នុងតំបន់ឆ្នេរ និងបណ្តាខេត្តក្នុងដែនទឹកសាប។

## ឯកសារយោង


1. Circular on the Establishment of Project Steering Committee, MOE 2012;
2. Circular on the Establishment of Working Group of Focal Officers, MOE, 2012;
3. Circular on the Establishment of Provincial Working Group for CARP, 2012;
4. DHI, 2012, "Assessment of Coping Strategies in the Coastal Zone of Cambodia";
5. DHI, 2012, "Vulnerability of Existing Agricultural Practices";
6. DHI, 2012 "Assessment of Community Vulnerability and Risk from Climate Change in Coastal Areas";
7. DHI, 2012 "Analysis of Cost and Benefits for Modifying Agricultural Practices in the Coast;
8. DHI, 2012 "Support to CC Education, Awareness Building and FWUC Strengthening";
9. DHI, 2013, "Detailed Implementation Plan for Demonstration Activities at the Coast", MOE/CCCA;
10. Inter-ministerial Joint Prakas, Dec. 2010, "Development of Development Plan and Investment Program", MOI & MOP.
11. Koh Kong Provincial Governor, "Five Year Development Plan of Koh Kong 2011-2015";
12. Law on Administrative Management of Capital/Provinces/Municipalities/Districts, 2008;
13. MOE, WB & ADB, 2013, "Private Sector Scoping Study: Engaging the Private Sector in Climate Change Adaptation Investments";
14. MoE/DHI, 2013 "Guidance on Mainstreaming Climate Resilience and Disaster Risk Reduction into Sub-National Development and Investment Planning";
15. MOI/DHI, 2013 "Case Study: Climate Proofing of Investment Projects in Takeo Province";
16. Royal Decree on the "Establishment of National Committee for Democratic Development at the Sub-National Level, MOI 2008;
17. Royal Decree on the "Establishment  of National Committee for Management and Development of Cambodian Coastal Areas", Feb 2012;
18. Sub-Decree on "General Processes of Transfer of Functions and Resources to the Sub-National Administrations", MOI, May 2012;
19. Sub-Decree on the "Establishment of National Climate Change Committee", April 2006;
20. Tariq, H Niazi, 2011, Decentralization and De-concentration Reforms in Cambodia, ADB.


## ឧបសម្ព័ន្ធ – ផែនការវិនិយោគឃុំ និងសំណើគម្រោងខ្នាតតូច

១. ឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

២. ឃុំទួលទទឹង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៣. ឃុំទឹកល្អក់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៤. ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៥. ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៦. ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

៧. ឃុំពាមក្រសោប ស្រុកមណ្ឌលសីមា ខេត្តកោះកុង

៨. ឃុំទួលគរគី ស្រុកមណ្ឌលសីមា ខេត្តកោះកុង